ក្រសួងសុខាភិបាល

មជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក



# គោលការណ៍ណែនាំជាតិ

# ស្តីពី

# ការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន

កែសំរួល និង បោះពុម្ពលើកទី២

ខែ កញ្ញា ឆ្នាំ ២០០៥

ឧបត្ថម្ភដោយ

ក្រសួងសុខាភិបាល
មជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក

# គោលការណ៍ណែនាំជាតិ
# ស្តីពី
# ការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន

កែសំរួល និង បោះពុម្ពលើកទី២

ខែ កញ្ញា ឆ្នាំ ២០០៥

# អក្សរកាត់តំណាងឱ្យពាក្យ

| | |
|---|---|
| AIDS | ជំងឺអេដស៍: ប្រជុំចង្កោមរោគសញ្ញាដោយសារប្រព័ន្ធភាពស៊ាំនៃរាងកាយចុះខ្សោយ |
| ANC | ការថែទាំផ្ទៃពោះមុនពេលសំរាល |
| ARV | ឱសថប្រឆាំងនឹងមេរោគអេដស៍ |
| CMS | ឃ្លាំងឱសថកណ្តាល |
| CoC | ការថែទាំនិងព្យាបាលបន្ត |
| CoC-CC | គណកម្មការសំរបសំរួលការថែទាំ និង ព្យាបាលបន្ត |
| ELISA | ប្រភេទតេស្តអេលីហ្សាសំរាប់បញ្ជាក់អង្គបដិបក្ខមេរោគអេដស៍ |
| GFATM | មូលនិធិសកលសំរាប់ប្រយុទ្ធនឹងជំងឺអេដស៍ របេង និង ជំងឺគ្រុនចាញ់ |
| HC | មណ្ឌលសុខភាព |
| HAART | ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍សកម្មបំផុត |
| HBC | ការថែទាំអ្នកជំងឺអេដស៍តាមផ្ទះ |
| HIV | មេរោគអេដស៍ |
| IEC | ផ្តល់ពត៌មាន អប់រំ និង ទំនាក់ទំនង |
| IMCI | សមាហរណកម្មព្យាបាលជំងឺកុមារ (សពជក) |
| MCH | សុខភាពមាតានិងទារក |
| MMM | មណ្ឌលមិត្តជួយមិត្ត |
| MoH | ក្រសួងសុខាភិបាល |
| MTCT | ការចំលងពីម្តាយទៅកូន |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ |
| NMCHC | មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| NVP | ឱសថប្រឆាំងមេរោគអេដស៍ នេវីរ៉ាពីន (Nevirapine) |
| OD | ស្រុកប្រតិបត្តិ |
| OI | ជំងឺឱកាសនិយម |
| OPD | ផ្នែកពិនិត្យជំងឺក្រៅ |
| PMTCT | ការបង្ការការចំលងពីម្តាយទៅកូន |

| | |
|---|---|
| PHD | មន្ទីរសុខាភិបាលខេត្ត |
| RH | សុខភាពបន្តពូជ |
| STI | ជំងឺកាមរោគ |
| SD | របបថ្នាំតែម្តងគត់ |
| TWG | ក្រុមការងារបច្ចេកទេស |
| TB | ជំងឺរបេង |
| ZDV | ឱសថប្រឆាំងមេរោគអេដស៍ ហ្សីដូវុយឌីន (Zidovudine) |
| VCCT | ការផ្តល់ប្រឹក្សា-ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ |

# អារម្ភកថា

នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងតែប្រឈមមុខទៅនឹងការរីករាលដាលនៃជំងឺអេដស៍ធ្ងន់ធ្ងរជាងគេបំផុតនៅក្នុងបណ្តាប្រទេសនៃតំបន់អាស៊ី ។ ក្នុងខណៈដែលអត្រាប្រេវ៉ាឡង់នៃការឆ្លងជំងឺអេដស៍ក្នុងស្រទាប់ក្រុមអ្នកប្រឈមខ្ពស់ (High risk group) បាននឹងកំពុងតែធ្លាក់ចុះជាលំដាប់នោះ អត្រាឆ្លងជំងឺអេដស៍ក្នុងចំណោមស្ត្រីមានគភ៌ដែលបានទទួលសេវាពិនិត្យផ្ទៃពោះហាក់ដូចជាមិនទាន់ចុះនៅឡើយ (២.២% នៅឆ្នាំ ២០០៣) ។ ដោយសារតែអត្រានៃការឆ្លងជំងឺអេដស៍មានកំណើនជាលំដាប់នៅលើស្ត្រីដែលស្ថិតនៅក្នុងវ័យបន្តពូជ ដូច្នេះការពង្រីកកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននៅទូទាំងប្រទេស គឺជាកត្តាសំខាន់ណាស់ ដើម្បីគ្របដណ្តប់ទូទាំងប្រទេស ។

មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកនៃក្រសួងសុខាភិបាលបានសហការជាមួយនឹងនាយកដ្ឋាននានា ស្ថាប័ននានា ព្រមទាំងបណ្តាអង្គការនានា ទាំងក្នុងស្រុកនិងអន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់ស្ត្រីព្រមទាំងដៃគូរបស់គាត់ ។ កម្មវិធីបង្ការ ការចំលងមេរោគអេដស៍ពីម្តាយទៅកូនត្រូវបានសមាហរណកម្មទៅក្នុងប្រព័ន្ធសេវាសុខភាពដែលមានស្រាប់ ។ កម្មវិធីនេះមិនគ្រាន់តែបង្ការការឆ្លងជំងឺអេដស៍ថ្មីតែប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យសេវាផ្តល់សុខភាពសំរាប់ស្ត្រីមានគភ៌កាន់តែល្អប្រសើរឡើង ។ មិនតែប៉ុណ្ណោះ កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនថែមទាំងបានផ្តល់នូវសេវាថែទាំ និងគាំទ្រដល់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍-ជំងឺអេដស៍ និងកូន ព្រមទាំងគ្រួសាររបស់គាត់ផងដែរ ។

មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក បានធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយនឹងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដើម្បីធានាឱ្យបានថាក្រុមការងារបង្ការការចំលងមេរោគអដស៍ពីម្តាយទៅកូន និងក្រុមការងារ ថែទាំបន្តអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ អាចនឹងធ្វើការរួមគ្នាក្នុងការធ្វើឱយអ្នកជម្ងឺទាំងនោះទទួលបាននូវការគាំទ្រដ៏ល្អមួយ និង ទទួលបាននូវសេវាថែទាំព្យាបាលដែលមានគុណភាព ។

ដើម្បីឱ្យកម្មវិធីនេះដំណើរការកាន់តែល្អប្រសើរ និង ដើម្បីលើកកំពស់គុណភាពសេវាសុខភាពមាតា និងទារកជាពិសេសក្នុងការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ក្រសួងសុខាភិបាលបានសំរេចធ្វើការកែសំរួលជាថ្មីឡើងវិញនូវគោលនយោបាយជាតិ និង គោលការណ៍ណែនាំជាតិស្តីពីការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនដែលបានផលិតនាឆ្នាំ២០០០ និង ឆ្នាំ២០០២ ។

គោលការណ៍ណែនាំនេះ មានទិសដៅជួយសំរួលដល់មន្ត្រីដែលបំរើការក្នុងវិស័យសុខាភិបាលឱ្យមានការងាយស្រួលក្នុងការអនុវត្តន៍ការតាមដាន និង ការវាយតំលៃសេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន នៅតាមស្ថាប័នសុខាភិបាលនានា ។

ភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥

សាស្ត្រាចារ្យ **អេង ហួត**

រដ្ឋលេខាធិការក្រសួងសុខាភិបាល

# សេចក្តីថ្លែងអំណរគុណ

កម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វេជ្ជបណ្ឌិត គ្រូពេទ្យ គិលានុបដ្ឋាក គិលានុបដ្ឋាយិកា និងឆ្មបទាំងអស់ដែលកំពុងបំពេញភារកិច្ចនៅទូទាំងប្រទេស កម្ពុជាដែលបានខិតខំធ្វើឱ្យសេវាសុខភាពមាតា និងទារកកាន់តែមានគុណភាពល្អប្រសើរឡើង ។ កម្មវិធីជាតិនឹងមិនអាចដំណើរការបានល្អទេ ប្រសិនបើគ្មានការចូលរួមពីអស់លោក-លោកស្រីទាំងអស់គ្នា ។

ខ្ញុំសូមថ្លែងអំណរគុណដល់អស់លោក-លោកស្រី ដែលជាមន្ត្រី-បុគ្គលិកនៃកម្មវិធីបង្ការការចំលងមេរោគអេដស៍ នៅមណ្ឌលសុខភាព ស្រុកប្រតិបត្តិ ថ្នាក់ខេត្ត និងនៅថ្នាក់ជាតិទាំងអស់ ចំពោះការប្តេជ្ញាចិត្ត និងការបូជាអស់កំលាំងកាយ ចិត្តរបស់អស់លោក-លោកស្រី ក្នុងការឆ្លើយតបទៅនឹងការរីករាលដាលនៃមេរោគអេដស៍-ជំងឺអេដស៍នៅប្រទេសកម្ពុជាយើងនេះ ។

ខ្ញុំសូមថ្លែងអំណរគុណដល់អស់លោក-លោកស្រី ជាសមាជិកនៃក្រុមការងារបច្ចេកទេសទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតំលៃផ្តល់នូវបទពិសោធន៏ការងារបច្ចេកទេសល្អៗ ជាគុណប្រយោជន៏ក្នុងការកែសំរួលគោលការណ៏ណែនាំជាតិនេះឡើងវិញ ។ ខ្ញុំសូមសំដែងការកោតសរសើរចំពោះឆន្ទៈរបស់ក្រុមការងារបច្ចេកទេសដែលបានធ្វើឱ្យកម្មវិធីបង្ការការចំលង មេរោគអេដស៍ពីម្តាយទៅកូនកាន់តែមានដំណើរការល្អប្រសើរ ។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់ លោកវេជ្ជ. ម៉ាស់ស៊ីម៉ូ ហ្គីឌីណែលី-តំណាងអង្គការសុខភាពពិភពលោក, លោកវេជ្ជ. កាហ្សូហ៊ីរ៉ូ កាគីម៉ូតូ-តំណាងអង្គការសហប្រតិបត្តិការអន្តរជាតិជប៉ុន, លោកវេជ្ជ. ឆាវ៉ាលីត ណាតប្រាថន-តំណាងអង្គការសុខភាពគ្រួសារអន្តរជាតិ, លោកស្រី ជិន សេដ្ឋា-តំណាងអង្គការសហប្រជាជាតិមូលនិធិដើម្បីកុមារ និងលោកស្រីវេជ្ជ. អ៊ឹង វិបុល តំណាងមន្ទីរពេទ្យកុមារជាតិ ដែលបានផ្តល់នូវមូលវិចារណ៏ និងអនុសាសន៏ដ៏មានអត្ថប្រយោជន៏និងយ៉ាងទូលំទូលាយ ។

ជាងនេះទៅទៀត ខ្ញុំសូមថ្លែងអំណរគុណដល់កញ្ញា នីកូល ដេវីត តំណាងមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក ដែលបានរៀបរៀងអត្ថបទ, លោកវេជ្ជ. នង កាណារ៉ា មន្ត្រីនៃមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក, លោកស្រីវេជ្ជ. រេជ្សិន ឡឺហ្វេ- តំណាង អង្គការសហប្រតិបត្តិការបារាំង, លោកវេជ្ជ. ឈុន ឡុង និងលោកស្រីវេជ្ជ. វង្ស សត្យាវ៉ានី មន្ត្រីនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ចំពោះការខិតខំផ្តល់ជាអនុសាសន៏ដ៏មានសារៈប្រយោជន៏ជាមួយនឹងការចំណាយពេលវេលាដ៏ច្រើនដើម្បីបញ្ចប់ការកែសំរួល និងចងក្រងសៀវភៅនេះឡើង ។

សេចក្តីថ្លែងអំណរគុណនេះ សូមជូនទៅដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគចំពោះ ការរួមសហការយ៉ាងល្អប្រសើរ និង សូមជូនដល់ក្រសួងសុខាភិបាល ចំពោះការគាំទ្រដល់កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ។

ភ្នំពេញ,ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥

សាស្ត្រាចារ្យ **គុំ ភាណារ៉ាល់**

ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក

# កម្មវិធីជាតិ PMTCT : អង្គការលេខ



# មាតិកា


**អក្សរកាត់តំណាងឱយពាក្យ** ........ i

**អារម្ភកថា** ........ iii

**សេចក្ដីថ្លែងអំណរគុណ** ........ v

**កម្មវិធីជាតិ PMTCT : អង្គការលេខ** ........ vii

**មាតិកា** ........ ix

**ជំពូកទី ១ : សេចក្ដីផ្ដើម** ........ **១**

១.១ គោលបំណងនៃគោលនយោបាយជាតិស្ដីពីការបង្ការការចំលងមេរោគអេដស៍ពីម្ដាយ ទៅកូន ........ ១

១.២ កញ្ចប់សកម្មភាពនៃការបង្ការការចំលងមេរោគអេដស៍ពីម្ដាយទៅកូន ........ ២

**ជំពូកទី ២ : ការផ្ដល់ប្រឹក្សា ការធ្វើតេស្ដឈាម និងការអប់រំ** ........ **៣**

២.១ ការផ្ដល់ប្រឹក្សា ........ ៣

២.២ ការធ្វើតេស្ដឈាម ........ ៥

២.៣ ពត៌មាន អប់រំ និង ទំនាក់ទំនង (IEC) ........ ៧

**ជំពូកទី ៣ : ឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលង** ........ **៨**

៣.១ របបឱសថសំរាប់បង្ការការចំលងមេរោគអេដស៍ពីម្ដាយទៅកូន ........ ៨

៣.២ ភាពងាយស្រួលដែលអាចធ្វើបាន ........ ៩

**ជំពូកទី ៤ : ការសំរាលកូនប្រកបដោយសុវត្ថិភាព** ........ **១១**

៤.១ ការបង្ការជាសកល ........ ១១

៤.២ ការសំរាលកូនដោយវះកាត់ ........ ១១

៤.៣ ការផ្ដល់ប្រឹក្សាក្រោយសំរាល ........ ១២

**ជំពូកទី ៥ : ការចិញ្ចឹមទារក និង ការតាមដានសុខភាពទារក** ........ **១៣**

៥.១ ការចិញ្ចឹមទារក ........ ១៣

៥.២ ការតាមដានសុខភាពទារក ........ ១៤

**ជំពូកទី ៦ : ផែនការគ្រួសារ** ........ **១៦**

៦.១ ផែនការគ្រួសារនិងមេរោគអេដស៍ ........ ១៦

៦.២ មធ្យោបាយផ្សេងៗនៃផែនការគ្រួសារ ........ ១៧

**ជំពូកទី ៧ : ការទទួលយកសេវាថែទាំបន្ត** ............ **១៨**

៧.១- ធ្វើសមាហរណកម្ម កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ទៅក្នុងប្រព័ន្ធសុខាភិបាលដែលមានស្រាប់ ............ ១៨

៧.២ យន្តការបង្អែក ............ ១៨

៧.៣ គណៈកម្មការសំរបសំរួលការថែទាំបន្ត ............ ១៩

**ជំពូកទី ៨ : ការអភិបាល និង ការត្រួតពិនិត្យគុណភាព** ............ **២០**

៨.១ ការអភិបាល ............ ២០

៨.២ ការត្រួតពិនិត្យគុណភាព ............ ២១

**ជំពូកទី ៩ : ការតាមដាននិងវាយតំលៃ** ............ **២២**

៩.១ ការប្រមូលទិន្នន័យ និង របាយការណ៍ ............ ២២

៩.២ ការតាមដានជាទៀងទាត់ ............ ២៤

៩.៣ ការវាយតំលៃ ............ ២៧

**ជំពូកទី ១០ : ការត្រៀមលក្ខណះសំរាប់ដំណើរការកម្មវិធីបង្ការ ការចំលងមេរោគអេដស៍ពីម្តាយទៅកូននៅមណ្ឌលថ្មី** ............ **២៨**

១០.១ ការជ្រើសរើសមណ្ឌល ............ ២៨

១០.២ ធនធានមនុស្ស ............ ២៩

១០.៣ ការបណ្តុះបណ្តាល ............ ២៩

១០.៤ សំភារៈបរិក្ខារ និងការផ្គត់ផ្គង់ ............ ៣០

**ឧបសម្ព័ន្ធ** ............ **៣១**

ឧបសម្ព័ន្ធ A : លិខិតព្រមព្រៀងសំរាប់ធ្វើតេស្តឈាម ............ ៣១

ឧបសម្ព័ន្ធ B : របបឱសថបង្ការប្រឆាំងមេរោគអេដស៍ សំរាប់បង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ............ ៣២

ឧបសម្ព័ន្ធ C : លិខិតបញ្ជូនសំរាប់ប្រើនៅ សេវាពិនិត្យផ្ទៃពោះ-អាគារ ពិនិត្យជំងឺក្រៅ ............ ៣៣

ឧបសម្ព័ន្ធ D : លិខិតបញ្ជូនពីសេវាពិនិត្យជំងឺក្រៅទៅ ............ ៣៤

ឧបសម្ព័ន្ធ E : បញ្ជីផ្ទៀងផ្ទាត់តាមដានប្រចាំខែសំរាប់មូលដ្ឋាន ............ ៣៥

ឧបសម្ព័ន្ធ F : បញ្ជីផ្ទៀងផ្ទាត់សំរាប់ការចុះអភិបាល ............ ៣៨

ឧបសម្ព័ន្ធ G : បែបបទសំរាប់ធ្វើការប៉ាន់ប្រមាណពីតំរូវការនៃកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ............ ៤៨

ឧបសម្ព័ន្ធ H : តួនាទីនៃមន្ត្រីកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ............ ៥១

References ............ ៥៦

# ជំពូកទី ១ : សេចក្តីផ្តើម

គោលការណ៍ណែនាំជាតិស្តីពីកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននេះផ្តល់នូវមូលដ្ឋានគ្រឹះជាស្តង់ដាជាបទដ្ឋានជាតិសំរាប់ប្រើប្រាស់ និង អនុវត្តនៅតាមបណ្តាមណ្ឌលដែលមានកម្មវិធី PMTCT ទាំងអស់នៅទូទាំងប្រទេសកម្ពុជា ក្នុងការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។ គោលការណ៍ណែនាំនេះ មានគោលបំណងផ្តល់នូវចំណេះដឹងដ៏មានសារៈប្រយោជន៍និងការណែនាំលំអិតស្តីពីការផ្តល់ប្រឹក្សា, ការចិញ្ចឹមកូន, ការថែទាំខាងផ្នែកសម្ភព, សេវាមន្ទីរពិសោធន៍, របបថ្នាំព្យាបាលបង្ការប្រឆាំងនឹងមេរោគអេដស៍, ការគ្រប់គ្រងកម្មវិធីនិងការតាមដានដំណើរការនៃកម្មវិធី PMTCT ដល់មន្ត្រី-បុគ្គលិកសុខាភិបាលដែលធ្វើការនៅតាមមណ្ឌលនិមួយៗ។ គោលការណ៍ណែនាំនេះក៏សង្កត់ធ្ងន់ផងដែរពីសារៈសំខាន់នៃការយល់ដឹងជាទូទៅអំពីការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន និងពត៌មានជាមូលដ្ឋានគ្រឹះស្តីពីមេរោគអេដស៍-ជំងឺអេដស៍។ គោលការណ៍ណែនាំនេះបានដកស្រង់ពីបទពិសោធន៍នៅតាមមណ្ឌលដែលកំពុងតែអនុវត្តកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននៅក្នុងប្រទេសកម្ពុជា, បានមកពីឯកសារអន្តរជាតិ, និងបានមកពីគោលនយោបាយជាតិស្តីពីការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។ ឯកសារយោងមួយចំនួនត្រូវបានប្រើប្រាស់ ដើម្បីធ្វើឱ្យគោលការណ៍ណែនាំនេះមានលក្ខណៈពេញលេញសំរាប់ជាជំនួយដល់មន្ត្រី-បុគ្គលិកសុខាភិបាលទាំងឡាយក្នុងការសិក្សាស្វែងយល់ពីពត៌មាន និង ការណែនាំផ្សេងៗបានស៊ីជំរៅតាមរយៈឯកសារទាំងនេះ (សូមមើលក្នុងទំព័រឯកសារយោង)។

## ១.១ គោលបំណងនៃគោលនយោបាយជាតិស្តីពីការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន

គោលនយោបាយជាតិស្តីពីការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនបានគូសបញ្ជាក់ថា

"កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនមានបំណងសំខាន់ :

- បង្ការស្ត្រី ដៃគូរួមភេទ រួមទាំងកូនរបស់គាត់ឱ្យជៀសផុតពីការឆ្លងមេរោគអេដស៍
- ការពារស្ត្រីផ្ទុកមេរោគអេដស៍ និងគ្រួសាររបស់គាត់ឱ្យជៀសផុតពីការរើសអើង និងមាក់ងាយ
- ផ្តល់សេវាថែទាំនិងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍និងធ្វើឱ្យបណ្តាញថែទាំសុខភាពនេះកាន់តែល្អប្រសើរឡើង
- រួមចំណែកក្នុងការលើកកំពស់ការទទួលបាន និងការប្រើប្រាស់សេវាសុខភាពដែលមានគុណភាព និង ទទួលបាននូវប្រព័ន្ធពត៌មានស្តីពីសុខភាពបន្តពូជ មេរោគអេដស៍-ជំងឺអេដស៍ និងជំងឺកាមរោគឱ្យកាន់តែមានភាពល្អប្រសើរឡើង។

ការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន គឺជាសមាសភាពមួយដ៏សំខាន់នៃយុទ្ធសាស្ត្របង្ការការចំលងមេរោគអេដស៍ និងទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍-ជំងឺអេដស៍ ដែលយុទ្ធសាស្ត្រនេះផ្តោតជាបថមលើសុខភាពបន្តពូជ នៃសេវាថែទាំសុខ ភាព" ។

## ១.២ កញ្ចប់សកម្មភាពនៃការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន

កញ្ចប់សកម្មភាពនៃការបង្ការនិងថែទាំសំរាប់ការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវតែបញ្ចូលទៅក្នុងសេវាសុខភាពមាតានិងទារក និង សេវាថែទាំជំងឺអេដស៍ដែលមានស្រាប់ ដើម្បីជៀសវាងនូវភាពរើសអើងផ្សេងៗ។ កញ្ចប់សកម្មភាពទាំងនេះ អនុវត្តតាមយុទ្ធសាស្រ្ត៤ដូចតទៅនេះ :

១)- ការបង្ការបឋម ដល់ស្ត្រីនិងដៃគូរួមភេទរបស់គាត់

២)- ការបង្ការស្ត្រីដែលមានផ្ទុកមេរោគអេដស៍ កុំឱ្យមានគភ៌ដោយចៃដន្យ

៣)- ការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន តាមរយៈសេវាសុខភាពមាតា និងទារក/សេវាសុខភាពបន្តពូជ/ សមាហរណកម្មព្យាបាលជំងឺកុមារ និងសេវាគ្រប់គ្រងជំងឺកាមរោគ ដែលជារួមមាន :

- ការផ្តល់ឱសថបង្ការប្រឆាំងមេរោគអេដស៍
- ការអនុវត្តន៍ការសំរាលកូនដែលប្រកបដោយសុវត្ថិភាព
- ការអនុវត្តន៍ការចិញ្ចឹមកូនដែលប្រកបដោយសុវត្ថិភាព

៤)- ការផ្តល់នូវការព្យាបាលថែទាំនិងគាំទ្រដល់ស្ត្រីផ្ទុកមេរោគអេដស៍-ជំងឺអេដស៍ ព្រមទាំងកូន និងគ្រួសាររបស់គាត់។

**កញ្ចប់សកម្មភាពសំរាប់អនុវត្តមាន :**

- ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ដល់ស្ត្រីមានគភ៌
- ការប្រើឱសថប្រឆាំងមេរោគអេដស៍ដើម្បីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន
- ការអនុវត្តន៍ការសំរាលកូនដែលប្រកបដោយសុវត្ថិភាព
- ការផ្តល់ប្រឹក្សា និង គាំទ្រសំរាប់ការចិញ្ចឹមកូនឱ្យមានសុវត្ថិភាព
- ការផ្តល់ប្រឹក្សាពីផែនការគ្រួសារ ឬការបញ្ជូនទៅសេវាពន្យារកំណើត
- ការបញ្ជូនទៅសេវាថែទាំ និង គាំទ្រសំរាប់ស្ត្រីផ្ទុកមេរោគអេដស៍ កូន និងគ្រួសាររបស់គាត់។

# ជំពូកទី ២ : ការផ្តល់ប្រឹក្សា ការធ្វើតេស្តឈាម និងការអប់រំ

## ២.១ ការផ្តល់ប្រឹក្សា

កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន អាចទទួលជោគជ័យបានអាស្រ័យលើការដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ស្ត្រីខ្លួនឯង។ ដូច្នេះ ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមមានតួនាទីសំខាន់ណាស់នៅគ្រប់មណ្ឌលដែលមានកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។ រាល់ស្ត្រីដែលមកទទួលសេវាពិនិត្យផ្ទៃពោះ ត្រូវបានណែនាំឱ្យចូលរួមក្នុងកម្មវិធីបង្ការការ ចំលងមេរោគអេដស៍ពីម្តាយទៅកូន ហើយនិងបានទទួលការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និង រក្សាការសំងាត់ (សូមមើលឧបសម្ព័ន្ធ A)។ អ្នកផ្តល់ប្រឹក្សាជួយលើកទឹកចិត្តដល់ដៃគូរួមភេទរបស់ស្ត្រីមានគិភឱ្យចូលរួមក្នុងសេវាផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាម។

បើសិនជាស្ត្រីមកពិនិត្យផ្ទៃពោះមានចំនួនច្រើនល្មម ត្រូវផ្តល់ការអប់រំដល់ស្ត្រីនៅថ្នាក់អប់រំម្តាយជាមុនសិន មុននឹងធ្វើការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមរកមេរោគអេដស៍ ដើម្បីផ្តល់ពត៌មានស្តីពីមេរោគអេដស៍-ជំងឺអេដស៍ និងការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន រួមជាមួយនឹងការអប់រំសុខភាពផ្សេងៗទៀត។ តែទោះបីជាយ៉ាងណាក៏ដោយការផ្តល់ប្រឹក្សាមុន និង ក្រោយពេលធ្វើតេស្តឈាម ត្រូវធ្វើនៅក្នុងបន្ទប់មួយដោយឡែកដើម្បីធានាឱ្យបាននូវការលាក់ការសំងាត់របស់អតិថិជន។

ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមដល់ស្ត្រី និង ដៃគូរួមភេទរបស់គាត់នូវពត៌មានជាមូលដ្ឋានស្តីពីមេរោគអេដស៍-ជំងឺអេដស៍ធ្វើឱ្យស្ត្រីដឹងពីទំរង់ការនៃការធ្វើតេស្តឈាម និងជួយឱ្យស្ត្រី និងដៃគូរបស់គាត់ស្វែងយល់ពីឥរិយាបថប្រឈមនឹងគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍របស់បុគ្គលម្នាក់ៗ។ ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមគួរតែបំពេញលើប្រធានបទដូចតទៅ :

- ពត៌មានជាមូលដ្ឋានស្តីពីមេរោគអេដស៍- ជំងឺអេដស៍
- ការវាយតំលៃទៅលើការយល់ដឹងរបស់អតិថិជនអំពីជំងឺកាមរោគ រួមទាំងមេរោគអេដស៍- ជំងឺអេដស៍
- ការចំលង និងការពារជំងឺកាមរោគ និង មេរោគអេដស៍
- ការវាយតំលៃ និង ពិភាក្សាទៅលើការប្រឈមនឹងការឆ្លងមេរោគអេដស៍របស់អតិថិជន
- ជំរើស និង ផែនការកាត់បន្ថយគ្រោះថ្នាក់ប្រឈមនឹងការឆ្លងមេរោគអេដស៍
- ការចំលងមេរោគអេដស៍ពីម្តាយទៅកូន និង ជំរើសសមស្របក្នុងការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន
- ទំរង់នៃការធ្វើតេស្តឈាម និង ការរក្សាការសំងាត់
- ផលប្រយោជន៍ និង ផលប៉ះពាល់នៃការធ្វើតេស្តឈាមរកមេរោគអេដស៍

- ការពន្យល់ពីលទ្ធផលតេស្តដែលវិជ្ជមាន និង អវិជ្ជមាន រួមទាំងការពន្យល់ពី "រយៈពេលចំហនៃមេរោគអេដស៍"
- ការបង្ហាញឱ្យអតិថិជនស្គាល់ពីសេវាគាំទ្រអ្នកជំងឺអេដស៍នានា។

> នៅពេលអតិថិជនត្រឡប់មកទទួលលទ្ធផលតេស្ត ត្រូវផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមជូនគាត់ម្តងទៀត ទោះបីជាលទ្ធផលនោះ វិជ្ជមានក្តី ឬអវិជ្ជមានក្តី។ គោលបំណងនៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមគឺដើម្បីៈ
>
> - ផ្តល់លទ្ធផលតេស្តរកមេរោគអេដស៍ដល់អតិថិជន
> - ធានាថាអ្នកជំងឺយល់ពីអត្ថន័យរបស់លទ្ធផលតេស្ត
> - ផ្តល់ពតិមានស្តីពីកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនអោយបានច្បាស់លាស់
> - ផ្តល់ការគាំទ្រពតិមាន និង ការបញ្ជូន
> - លើកទឹកចិត្តឱ្យអតិថិជនធ្វើការផ្លាស់ប្តូរឥរិយាបថដើម្បីកាត់បន្ថយការប្រឈមនឹងគ្រោះថ្នាក់ និង លើកទឹកចិត្តឱ្យមានការចូលរួមពីដៃគូក្នុងការធ្វើតេស្តឈាម។
>
> *Adapted from: WHO/CDC. 2004. Prevention of Mother-to-Child Transmission of HIV Generic Training Package.*

ចំពោះស្ត្រីដែលមានលទ្ធផលតេស្តអវិជ្ជមាន : ក្នុងពេលផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាម អ្នកផ្តល់ប្រឹក្សាត្រូវផ្តល់នូវពតិមានបន្ថែមដល់ស្ត្រីដូចតទៅ :

- ពន្យល់ជាសង្ខេបដល់អតិថិជនពីផែនការសំរាប់កាត់បន្ថយការប្រឈមនឹងគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ទៅតាមកាលៈទេសៈសមស្រប រួមទាំងផ្តល់ពតិមានស្តីពីរបៀបការពារកុំឱ្យឆ្លងមេរោគអេដស៍នាពេលអនាគត។
- ពន្យល់ស្ត្រីពីការប្រឈមខ្ពស់ទៅនឹងការចំលងមេរោគអេដស៍ទៅទារក ប្រសិនបើគាត់ក្លាយទៅជាមានផ្ទុកមេរោគអេដស៍ក្នុងពេលដែលកំពុងមានគភ៌ ឬ ពេលកំពុងបំបៅកូនដោយដោះ។
- ជំរាបឱ្យស្ត្រីដឹងថា គាត់អាចមកពិគ្រោះយោបល់បានទៀតនៅពេលខាងមុខ ប្រសិនជាគាត់ត្រូវការ។
- ធានាឱ្យបានថា ស្ត្រីបានយល់ច្បាស់ពីរយៈពេលចំហនៃមេរោគអេដស៍ ដែលតំរូវឱ្យធ្វើគាត់មកធ្វើតេស្តឈាមម្តងទៀតនៅ៣ខែក្រោយ បើសិនជាអាចធ្វើបាន។

ចំពោះស្ត្រីដែលមានលទ្ធផលតេស្តវិជ្ជមាន : ក្នុងពេលផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត អ្នកផ្តល់ប្រឹក្សាត្រូវផ្តល់ពតិមានបន្ថែមដល់ស្ត្រីដូចតទៅ :

- ការពិភាក្សាពីអត្ថន័យនៃលទ្ធផលតេស្ត ពីអារម្មណ៍ និងពីការប៉ះទង្គិចផ្លូវចិត្តដែលអាចកើតមានភ្លាមៗ ក្រោយពីដឹងនូវលទ្ធផលតេស្ត

- ឆ្លើយតបទៅនឹងសំនួរ ឬការបារម្ភណាមួយរបស់អតិថិជន ដែលទាក់ទងទៅនឹងលទ្ធផលតេស្ត
- ផ្តល់ប្រឹក្សាដល់អតិថិជនឱ្យគាត់ចេះរកវិធីដោះស្រាយបញ្ហា និង ការបារម្ភផ្សេងៗដែលអាចកើតមានភ្លាមៗ
- ជំរាបឱ្យគាត់បានដឹងពីសេវាព្យាបាលជំងឺរបេង សេវាព្យាបាលជំងឺឱកាសនិយមនិងជំងឺអេដស៍ដោយឱសថប្រឆាំងមេរោគអេដស៍ និងសេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន (TB, OI /ARV និង PMTCT) ដើម្បីឱ្យគាត់អាចមកទទួលសេវាទាំងនេះបាន
- ពិភាក្សាពីផលប៉ះពាល់ និង ផលប្រយោជន៍នៃការប្រាប់ពីស្ថានភាពផ្ទុកមេរោគអេដស៍របស់គាត់ឱ្យអ្នកដទៃទៀតបានដឹង និង ការធ្វើតេស្តឈាមរកមេរោគអេដស៍របស់ដៃគូរួមភេទ
- ពន្យល់ពីសារៈសំខាន់នៃការសំរាលកូននៅក្នុងមន្ទីរពេទ្យ ឬ មណ្ឌលសុខភាពដែលមានផ្តល់សេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។
- ផ្តល់ប្រឹក្សាដល់ស្ត្រីពីជីវិតរស់នៅ និង ការតស៊ូជាមួយនឹងមេរោគអេដស៍
- ពន្យល់អោយបានច្បាស់លាស់ពីជំរើសនៃការចិញ្ចឹមទារក។

ឯកសាររបស់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍ ត្រូវរក្សាទុកនៅក្នុងកន្លែងមួយជាសំងាត់ និងមានសុវត្ថិភាពល្អគ្រប់ពេលវេលាទាំងអស់។

## ២.២ ការធ្វើតេស្តឈាម

គ្រប់បុគ្គលិកមន្ទីរពិសោធន៍ដែលទទួលខុសត្រូវលើការធ្វើតេស្តឈាមរកមេរោគអេដស៍ ត្រូវទទួលការបណ្តុះបណ្តាលពីការធ្វើតេស្ត ឈាមរកមេរោគអេដស៍ដែលផ្តល់ដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ។រាល់ការធ្វើតេស្តឈាម ត្រូវតែអនុវត្តតាមគោលនយោបាយជាតិនិងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាមរកមេរោគអេដស៍របស់ ក្រសួងសុខាភិបាលដែលផលិតដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ។ ការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយអ្នកដែលមិនមែនជាបុគ្គលិកមន្ទីរពិសោធន៍ (ដូចជាអ្នកផ្តល់ប្រឹក្សាជាដើម) មិនត្រូវបានអនុញ្ញាតឱ្យធ្វើទេ នៅពេលបច្ចុប្បន្ននេះ។

ការធ្វើតេស្តឈាមរកមេរោគអេដស៍សំរាប់ស្ត្រីមានគភ៌ ត្រូវរួមបញ្ចូលជាមួយសេវាផ្តល់ប្រឹក្សានៅផ្នែកពិនិត្យផ្ទៃពោះ។ អ្នកផ្តល់ប្រឹក្សានៃកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវអនុវត្តការបូមឈាមអតិថិជនតាមទំរង់ការដូចខាងក្រោមនេះ :

១. មុនពេលបូមឈាមអតិថិជនដើម្បីយកទៅមន្ទីរពិសោធន៍ពិនិត្យរកមេរោគអេដស៍អ្នកផ្តល់ប្រឹក្សាត្រូវទទួលបានការយល់ព្រមជាលាយល័ក្ខអក្សរពីអតិថិជនជាមុនសិន ក្រោយពីផ្តល់ពត៌មានគ្រប់គ្រាន់ដល់អតិថិជនរួចហើយ ។

២. បិទផ្លាកដែលមានលេខកូដរបស់អតិថិជនលើបំពង់ទីបឈាម និង សរសេរលេខកូដព្រមទាំងថ្ងៃខែធ្វើតេស្ត ឈាមរបស់អតិថិជនដាក់ក្នុងសៀវភៅបញ្ជីកត់ត្រាអោយបានត្រឹមត្រូវ ។

៣. ពាក់ស្រោមដៃនៅពេលបូមឈាមអតិថិជនចូលក្នុងបំពង់ទីបឈាម ។ *ស្រោមដៃដែលពាក់រួចហើយមិនត្រូវប្រើលើអតិថិជនម្នាក់ទៀតទេ ។*

៤. បញ្ជូនឈាមទៅមន្ទីរពិសោធន៍អោយបានរហ័សតាមដែលអាចធ្វើទៅបានសំរាប់ការធ្វើតេស្តឈាម ។

ប្រធានក្រុមអ្នកផ្តល់ប្រឹក្សានៃកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន និងប្រធានមន្ទីរពិសោធន៍ត្រូវមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ដើម្បីសំរួលដល់ការបញ្ជូនឈាមពីមណ្ឌលសុខភាពទៅមន្ទីរពិសោធន៍ និង ការទទួលលទ្ធផលតេស្តឈាមពីមន្ទីរពិសោធន៍ទៅមណ្ឌលសុខភាព ។ លទ្ធផលតេស្តឈាមត្រូវផ្តល់ឱ្យអតិថិជននៅក្នុងថ្ងៃតែមួយ បើសិនជាអាចធ្វើបាន ។ ទំនាក់ទំនងរវាងមណ្ឌលសុខភាព និងមន្ទីរពិសោធន៍ជាកត្តាសំខាន់ណាស់ ។ ពិធីសារនៃការធ្វើតេស្តឈាមត្រូវបានផលិតដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ដើម្បីអាចបញ្ជាក់ថា ឈាមដែលយកមកពិនិត្យនោះមានផ្ទុកមេរោគអេដស៍ ឬមិនមានផ្ទុកមេរោគអេដស៍ ។

ពិធីសារនៃការធ្វើតេស្តដូចខាងក្រោមនេះត្រូវបានប្រើប្រាស់នៅពេលបច្ចុប្បន្ននេះក្នុងប្រទេសកម្ពុជា:

- គ្រប់សេរ៉ូម/ប្លាស្មាត្រូវបានវិភាគជាដំបូងដោយតេស្តរហ័ស ។
- សេរ៉ូមដែលគ្មានប្រតិកម្មជាមួយនឹងតេស្តលើកទីមួយទេនោះ ចាត់ទុកថាមិនមានអង្គបដិបក្ខរបស់មេរោគអេដស៍ទេ ។
- សេរ៉ូមដែលមានប្រតិកម្មជាមួយនឹងការវិភាគលើកទីមួយត្រូវបានគេធ្វើតេស្តម្តងទៀតជាមួយនឹងតេស្តរហ័សមួយផ្សេងទៀត រឺ តេស្ត ELISA ។
- សេរ៉ូមដែលមានប្រតិកម្មជាមួយតេស្តទាំងពីរនេះ ត្រូវបានចាត់ទុកថា មានអង្គបដិបក្ខរបស់មេរោគអេដស៍ ។
- សេរ៉ូមដែលមានប្រតិកម្មជាមួយតេស្តទីមួយតែគ្មានប្រតិកម្មជាមួយនឹងតេស្តទីពីរ ត្រូវតែធ្វើតេស្តម្តងទៀតជាមួយនឹងតេស្តទាំងពីរមុខនោះ នៅលើសេរ៉ូមដដែល ។
- លទ្ធផលដែលត្រូវគ្នាបន្ទាប់ពីការធ្វើតេស្តម្តងទៀតនោះ នឹងបញ្ជាក់ថា លទ្ធផលតេស្តវិជ្ជមាន ឬក៏អវិជ្ជមាន ។
- ប្រសិនបើលទ្ធផលរបស់តេស្តនៅតែមិនត្រូវគ្នា គេចាត់ទុកថាសេរ៉ូមនោះមិនអាចកំនត់បាន ហើយគេត្រូវបូមឈាមអតិថិជនជាថ្មីម្តងទៀត ដើម្បីពិនិត្យសាឡើងវិញ ។ (នៅពេលណា?)

*Source: NCHADS.2002. Policy, Strategy and Guidelines for HIV Counseling and Testing.*

នៅពេលណាដែលតេស្តរកមេរោគស្វាយ អាចរកបាន អាចទទួលយកបាន អាចធ្វើទៅបាន និងមានការយល់ព្រមពីអតិថិជន ឈាមដែលបូមសំរាប់រកមេរោគអេដស៍គួរតែប្រើដើម្បីរកមេរោគស្វាយផងដែរ ។ ប្រសិនបើការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោមរោគសញ្ញាឃើញថា អតិថិជនមានជំងឺកាមរោគត្រូវបញ្ជូនគាត់ទៅព្យាបាលនៅគ្លីនិកជំងឺកាមរោគ ។

ទំរង់ការត្រួតពិនិត្យគុណភាពដែលបង្កើតឡើងដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគត្រូវតែអនុវត្តតាមគ្រប់កាលៈទេសៈ ។ ទំរង់ការទាំងនេះរួមមានការត្រួតពិនិត្យគុណភាពនៃការបូមឈាម ការស្តុកឈាម និងការធ្វើតេស្តឈាម ។ អ្នកអភិបាលមន្ទីរពិសោធន៍នៅឯមន្ទីរពិសោធន៍បង្អែកទទួលខុសត្រូវលើការតាមដានគុណភាពរបស់លទ្ធផលតេស្តរៀងរាល់បីខែម្តង ។

## ២.៣ ពត៌មានអប់រំ និង ទំនាក់ទំនង (IEC)

ការធ្វើយុទ្ធនាការផ្សព្វផ្សាយពត៌មាន អប់រំ និង ទំនាក់ទំនង ជួយធ្វើឱ្យការមកទទួលសេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនកាន់តែមានភាពល្អប្រសើរឡើង និង ជួយការពារនូវភាពរើសអើង និងភាពមាក់ងាយទៀតផង ។ រាល់យុទ្ធវិធីផ្សព្វផ្សាយពិតមានអប់រំ និង ទំនាក់ទំនងដែលមានគោលដៅផ្តល់ពត៌មានស្តីពីមេរោគអេដស៍-ជំងឺអេដស៍ ត្រូវដាក់បញ្ចូល និងសង្កត់ធ្ងន់លើកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនផងដែរ ។ សម្ភារៈ IEC សមស្របសំរាប់ផ្សព្វផ្សាយពិតមានដូចជា ផ្ទាំងរូបភាពធំៗ ខិតប័ណ្ណ និងខ្សែវីដេអូអប់រំផ្សេងៗ ដែលមានគោលបំនងផ្តល់ចំនេះដឹងនិងផ្លាស់ប្តូរឥរិយាបថនៃការប្រព្រឹត្តិរបស់អតិថិជន និងអ្នកផ្តល់សេវានឹងត្រូវបានចែកចាយនៅពេលដែលសំភារៈទាំងនោះបានផលិតរួច ។

# ជំពូកទី ៣ : ឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលង

## ៣.១ របបឱសថសំរាប់បង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន

ការប្រើឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលង បានបង្ហាញពីប្រសិទ្ធិភាពខ្លាំងក្លាក្នុងការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ។ គ្រប់ស្រ្តីមានគិភដែលមានផ្ទុកមេរោគអេដស៍ ត្រូវប្រើឱសថប្រឆាំងមេរោគអេដស៍តាមទំរង់បែបបទដូចតទៅនេះ :

ប្រសិនបើលទ្ធផលតេស្តបង្ហាញថា ស្រ្តីមានគិភមានផ្ទុកមេរោគអេដស៍ ត្រូវបញ្ជូនគាត់ទៅផ្នែកពិនិត្យជំងឺក្រៅដែលនៅទីនោះ មានសេវាព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (OI/ART) សំរាប់ផ្តល់ជូនគាត់ ។ នៅទីនោះគាត់នឹងត្រូវបានវាយតំលៃពីលទ្ធភាពដែលអាចប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ដែលសកម្មបំផុត (HAART) ។

**ស្ថានភាព** A **:** ស្រ្តីមានគិភដែលមានលក្ខណៈគ្រប់គ្រាន់នឹងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគ អេដស៍ដែលសកម្មបំផុតនៅផ្នែកពិនិត្យជំងឺក្រៅដែលមានសេវា OI/ART ។

**ករណីទី១ :** ស្រ្តីដែលមានលក្ខណៈគ្រប់គ្រាន់នឹងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ស្រ្តីស្ថិតក្នុងដំណាក់កាលគ្លីនិកទី៤ របស់អង្គការសុខភាពពិភពលោក ឬ កោសិកា CD4 មានចំនួនតិចជាង២៥០)

- ប្រសិនបើស្រ្តីគ្មានជំងឺស្លេកស្លាំងទេ ត្រូវផ្តើមព្យាបាលដោយឱសថ ZDV+3TC+NVP អោយបានឆាប់រហ័សបំផុត តាមដែលអាចធ្វើទៅបាន (ផ្តើមព្យាបាលឱ្យបានរហ័ស) ។ ផ្ទុយទៅវិញ ប្រសិនបើស្រ្តីមានជំងឺស្លេកស្លាំង ត្រូវចាប់ផ្តើមព្យាបាលដោយការប្រើឱសថ DT4+3TC+NVP អោយបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។
- ម្តាយត្រូវបន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដែលសកម្មបំផុត តទៅទៀតក្នុងពេលសំរាល ។
- ទារកត្រូវទទួល :
    - ឱសថស៊ីរ៉ូប NVP (2mg/kg) ចំនួន១ដូស ក្នុងកំឡុងពេល៧២ម៉ោងដំបូងក្រោយសំរាល
    - ឱសថស៊ីរ៉ូប Zidovidine (ZDV) (4mg/kg) ២ដងក្នុងមួយថ្ងៃ រយៈពេលមួយសប្តាហ៍ ។

✷ *ប្រសិនបើម្តាយទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដែលសកម្មបំផុត តិចជាងបួនសប្តាហ៍ក្នុងកំលុងពេលមានគិភត្រូវផ្តល់ឱសថស៊ីរ៉ូប ZDV(4mg/kg) ដល់កូន ២ដងក្នុងមួយថ្ងៃ ឱ្យបានរយៈពេលបួនសប្តាហ៍ដំបូងក្រោយសំរាល ។*

**ករណីទី ២** : ស្ត្រីដែលមិនទាន់មានលក្ខណៈគ្រប់គ្រាន់នឹងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដែលសកម្មបំផុត (ដំណាក់កាលគ្លីនិកទី១ ទី២ ឬទី៣ ឬក៏កោសិកា CD4 មានចំនួនច្រើនជាង ២៥០) ឬក៏កន្លែងផ្តល់សេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននោះពុំទាន់មានសេវា (OI/ART) នៅឡើយ ។

- ម្តាយត្រូវទទួល :
  - ឱសថ ZDV (300mg) ពីរដងក្នុងមួយថ្ងៃ ដោយចាប់ផ្តើមប្រើពីអាទិត្យទី ២៨ នៃគភ៌ ឬបើសិនជាគាត់មកក្រោយ ២៨ អាទិត្យនៃគភ៌ត្រូវផ្តល់ជូនគាត់អោយបានឆាប់បំផុតតាមដែលអាចធ្វើបាន ។
  - ឱសថ ZDV (300mg) ត្រូវផ្តល់ឱ្យនៅពេលចាប់ផ្តើមឈឺពោះសំរាល និងត្រូវឱ្យរៀងរាល់៣ម៉ោងម្តងរហូតដល់ពេលសំរាល ។
  - ឱសថ NVP (200mg) មួយគ្រាប់នៅពេលឈឺពោះសំរាល
  - ឱសថ ZDV និង 3TC ២ដង ក្នុង ១ថ្ងៃ ប្រើរយៈពេលមួយអាទិត្យដំបូងក្រោយសំរាល (ការប្រើនេះអាចកាត់បន្ថយភាពស៊ាំជាមួយនឹងឱសថ NVP ។
- កូនត្រូវទទួល :
  - ឱសថស៊ីរ៉ូប NVP (2mg/kg) ឱ្យតែម្តង ក្នុងកំឡុងពេល៧២ម៉ោងដំបូងក្រោយសំរាល
  - ឱសថស៊ីរ៉ូប ZDV(4mg/kg) ២ដងក្នុង១ថ្ងៃ ឱ្យរយៈពេល១អាទិត្យ

✷ *បើសិនជាម្តាយបានទទួលឱសថ ZDV តិចជាង៤សប្តាហ៍ក្នុងកំឡុងពេលមានគភ៌ ត្រូវផ្តល់ឱសថស៊ីរ៉ូប ZDV ដល់កូន ២ដងក្នុង១ថ្ងៃ ឱ្យរយៈពេល៤សប្តាហ៍ដំបូងក្រោយសំរាល ។*

**ស្ថានភាព** B : ចំពោះស្ត្រីដែលមិនបានទទួលឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលង (មាន SD NVP ឬ ZDV) នៅពេលមានមានគភ៌ឬនៅពេលឈឺពោះសំរាល ( ឧ : ម្តាយមិនបានមកទទួលសេវាពិនិត្យផ្ទៃពោះ និង មកមន្ទីរពេទ្យក្នុងកំឡុង ពេលតិចជាងពីរម៉ោងមុនពេលសំរាល) ។

- ត្រូវផ្តល់ឱ្យកូន :
  - ស៊ីរ៉ូប NVP ចំនួន១ដូស (2mg/kg) ក្នុងកំឡុងពេល ៧២ម៉ោងដំបូងក្រោយពេលសំរាល
  - ស៊ីរ៉ូប ZDV (4mg/kg) ២ដងក្នុង១ថ្ងៃ រយៈពេល៤សប្តាហ៍ដំបូងក្រោយសំរាល

(សូមមើលឧបសម្ព័ន្ធ B បង្ហាញពីតារាងសំរាប់ការជ្រើសរើសការផ្តល់ឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលង) ។

## ៣.២ ភាពងាយស្រួលដែលអាចធ្វើបាន

ការផ្តល់ឱសថ ZDV ដល់ស្ត្រីមានគភ៌ត្រូវគោរពតាមល័ក្ខខ័ណ្ឌមួយចំនួន :

- មណ្ឌលបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវតែមានគ្រូពេទ្យ ឬឆ្មបដែលបានទទួលការបណ្តុះបណ្តាលពីការប្រើប្រាស់ឱសថ ZDV, ពីផលប៉ះពាល់របស់វា, និង ពីសារៈសំខាន់នៃការប្រើប្រាស់ឱសថឱ្យបានត្រឹមត្រូវ និង ជាប់លាប់ល្អ រួមទាំងការតាមដានម្តាយផង ជាប្រការចាំបាច់ណាស់ ។

- មន្ទីរពិសោធន៍នៅមណ្ឌលបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវធ្វើតេស្ត Hemoglobin ឬ Hematocrit ឱ្យត្រឹមត្រូវពិតប្រាកដ។
- ស្ត្រីមានគិភដែលមានផ្ទុកមេរោគអេដស៍ត្រូវធ្វើតេស្ត Hemoglobin ឬ Hematocrit ទុកជាគោល ដើម្បីបញ្ជាក់ ថាស្ត្រីគ្មានជំងឺស្លេកស្លាំងដែលបណ្តាលមកពីខ្វះឈាមក្រហមទេ។ ស្ត្រីត្រូវប្រាកដថាគាត់នឹងវិលមកមណ្ឌលសុខភាពវិញ រាល់២សប្តាហ៍ម្តងនៅខែទី១នៃការប្រើឱសថ ដើម្បីធ្វើការតាមដាន Hemoglobin ឬ Hematocrit ។ បន្ទាប់ពីខែទី ១ ស្ត្រីត្រូវមកមណ្ឌលសុខភាពដើម្បីពិនិត្យតេស្ត Hemoglobin ឬ Hematocrit ១ខែម្តងរហូតដល់ពេលសំរាល។ បើសិន Hemoglobin< ៩ ឬ Hematocrit< ៣៣% ត្រូវបញ្ឈប់ការប្រើ ZDV រហូតដល់លែងមានភាពស្លេកស្លាំងក្រោយពីព្យាបាលទើបឱ្យប្រើវិញ។
- មណ្ឌលបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនត្រូវមានឱសថជាតិដែកសំរាប់ផ្តល់ឱ្យស្ត្រីមានគិភ ហើយត្រូវអប់រំគាត់ឱ្យលេបឱសថជាតិដែក ដើម្បីការពារ និងត្រួតពិនិត្យជំងឺស្លេកស្លាំង។
- ស្ត្រីមានគិភត្រូវយល់ពីសារៈសំខាន់នៃការប្រើប្រាស់ឱសថជាប់លាប់ និងត្រឹមត្រូវ ហើយត្រូវលេបឱ្យបាន ២ដង ក្នុង ១ថ្ងៃ រហូតដល់ពេលសំរាលកូន។
- ស្ត្រីមានគិភត្រូវមកសំរាលកូននៅមន្ទីរពេទ្យដែលមានឱសថបង្ការប្រឆាំងមេរោគអេដស៍ដើម្បីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។

# ជំពូកទី ៤ ៖ ការសំរាលកូនប្រកបដោយសុវត្ថិភាព

## ៤.១ ការបង្ការជាសកល

មន្ត្រី-បុគ្គលិកសុខាភិបាលត្រូវតែគោរពឱ្យបាននូវគោលការណ៍បង្ការជាសកលចំពោះគ្រប់ស្ត្រីទាំងអស់ដែលមកសំរាលកូន ដោយមិនគិតពីស្ថានភាពផ្ទុកមេរោគអេដស៍ឬមិនផ្ទុករបស់គាត់ឡើយ ។

ការអនុវត្តន៍ការបង្ការជាសកលមានដូចតទៅៈ

- លាងដៃជាមួយសាប៊ូ និងទឹកបន្ទាប់ពីប៉ះពាល់ជាមួយឈាម និងសារធាតុរាវរបស់សរីរាង្គកាយ
- រំងាប់មេរោគ ឬ កាត់ផ្តាច់ការចំលងរោគ[1] លើសំភារៈឧបករណ៍ដែលប្រើប្រាស់ នៅពេលធ្វើការវះកាត់ឬសំរាលកូន
- មិនត្រូវយកគំរបម្ជុលទៅគ្របលើម្ជុលដែលប្រើរួចទេ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារការមុតម្ជុល
- ប្រើម្ជុលឬកាំបិតនៅលើអ្នកជំងឺតែម្នាក់ប៉ុណ្ណោះ
- ដាក់ម្ជុលដែលប្រើរួចទៅក្នុងប្រអប់សុវត្ថិភាព និងមិនជ្រាបទឹក
- ពាក់ស្រោមដៃនៅពេលដែលប៉ះពាល់ជាមួយនឹងសារធាតុរាវរបស់សរីរាង្គ, ស្បែកដែលដាច់រលាត់, ឬប៉ះពាល់ជាមួយនឹងស្រទាប់ជាលិកា
- គ្របស្បែករបស់អ្នកដែលដាច់រលាត់ ដោយប្រើបង់ស្អិតដែលមិនជ្រាបទឹក
- ពាក់អាវអៀមដែលមិនជ្រាបទឹក និងវ៉ែនតាការពារភ្នែក នៅពេលវះកាត់ ឬសំរាលកូន
- សំអាតឈាម ឬសារធាតុរាវផ្សេងៗដែលប្រឡាក់ឱ្យបានរហ័ស និងដោយប្រយ័ត្នប្រយែង
- ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រមូល និងចាក់ចោលសំរាម

*Adapted from: WHO/CDC 2004, Prevention of Mother-to-Child Transmission of HIV Generic Training Package.*

## ៤.២ ការសំរាលកូនដោយវះកាត់

ការសំរាលកូនដោយវះកាត់អាចកាត់បន្ថយការប្រឈមនឹងការចំលងមេរោគអេដស៍ពីម្តាយទៅកូន បើប្រៀបធៀបទៅនឹងការសំរាលកូនតាមទ្វារមាស ។ តែទោះបីជាយ៉ាងណាក៏ដោយ វិធីនេះប្រឈមទៅនឹងផលវិបាកជាច្រើនទាក់ទងទៅនឹងការវះកាត់ដែលនៅក្នុងនោះមានការឆ្លងរោគក្រោយវះកាត់ និងការសំរាលមិនគ្រប់ខែ ។ ហេតុដូច្នេះហើយការសំរាលកូនដោយវះកាត់មិនត្រូវបានណែនាំឱ្យធ្វើជាប្រចាំគ្រប់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍ទេ ។ ការសំរាលដោយវះកាត់ត្រូវធ្វើទៅតាមល័ក្ខខ័ណ្ឌ ដែលតំរូវជាលក្ខណៈស្តង់ដានៃផ្នែកសម្ភពតែប៉ុណ្ណោះ ។

សកម្មភាពផ្សេងៗ ដែលជួយឱ្យការសំរាលមានសុវត្ថិភាពមាន ៖

- ជៀសវាងការជួសបំបែកស្រោមទឹកភ្លោះ បើសិនជាមិនមែនជាករណីចាំបាច់

[1] ដកស្រង់ពីគោលការណ៍ណែនាំស្តីពីការបង្ការជាសកលសំរាប់ស្ថាប័នសុខាភិបាល របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគឆ្នាំ២០០២ ។

- ជៀសវាងកាត់ទ្វារមាសម្តាយ បើសិនជាមិនចាំបាច់ទេ
- កាត់បន្ថយការបូម ឬ ប្រើដង្កៀបកៀបយកកូន ឱ្យបានជាអតិបរិមា
- កាត់បន្ថយការធ្លាក់ឈាមក្រោយសំរាលឱ្យបានជាអតិបរិមា
- អនុវត្តការបង្ការជាសកល

*Adapted from: WHO/CDC. 2004, Prevention of Mother-to-Child Transmission of HIV Generic Training Package.*

## ៤.៣ ការផ្តល់ប្រឹក្សាក្រោយសំរាល

ក្រោយពេលសំរាល ឆ្មបនៅផ្នែកសំរាលត្រូវផ្តល់ប្រឹក្សាដល់ម្តាយពីរបៀបចិញ្ចឹមកូនឱ្យបានសមស្របថែមទៀត (សូមមើលផ្នែកចិញ្ចឹមកូន) ។ មិនថាតើស្ត្រីមានផ្ទុកមេរោគអេដស៍ឬអត់នោះទេ គ្រប់ម្តាយទាំងអស់ត្រូវបានទទួលការអប់រំក្រោយសំរាលស្តីពីតំរូវការអាហាររូបត្ថម្ភនៃកូន និង ការផ្តល់វ៉ាក់សាំងដល់កូន ។

សេវាផែនការគ្រួសារក៏ត្រូវផ្តល់ជូនដល់ស្ត្រីគ្រប់រូបដែរ ក្រោយពេលសំរាលកូនរួច រួមទាំងស្ត្រីដែលមានផ្ទុកមេរោគអេដស៍ផង ដើម្បីជៀសវាងការមានកូនដោយចៃដន្យ នាពេលអនាគត ។ អ្នកផ្តល់ប្រឹក្សាគួរប្រើពេលវេលានេះដើម្បីរំលឹកដល់ស្ត្រីមានផ្ទុកមេរោគអេដស៍ ពីសេវាថែទាំព្យាបាលនិងគាំទ្រដែលគាត់អាចទទួលបានដូចជា មណ្ឌលមិត្តជួយមិត្ត, ក្រុមថែទាំអ្នកជំងឺអេដស៍តាមផ្ទះ និងសេវាព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។

# ជំពូកទី ៥ : ការចិញ្ចឹមទារក និង ការតាមដានសុខភាពទារក

## ៥.១ ការចិញ្ចឹមទារក

ការចំលងមេរោគអេដស៍ពីម្តាយទៅកូនអាចកើតមានតាមរយៈការបំបៅដោះ ។ ក៏ប៉ុន្តែកុមារដែលមិនបានចិញ្ចឹមដោយដោះម្តាយ ក៏អាចប្រឈមនឹងការស្លាប់ដោយជំងឺរាករូស កង្វះចំណីអាហារ និងជំងឺរលាកផ្លូវដង្ហើមដោយសារតែទឹកដោះគោម្សៅតាមរូបមន្ត ឬ អាហាររូបត្ថម្ភបន្ថែមត្រូវបានរៀបចំដោយគ្មានសុវត្ថិភាព។ ដូច្នេះ អ្នកជំនាញខាងការផ្តល់ប្រឹក្សាត្រូវជួយស្ត្រីដែលមានផ្ទុកមេរោគអេដស៍ទាំងអស់ឱ្យទទួលបាននូវពិតមានច្បាស់លាស់ស្តីពីការចិញ្ចឹមកូន ដើម្បីអាចឱ្យគាត់ធ្វើការសំរេចចិត្តជ្រើសវិធីចិញ្ចឹមកូនរបស់គាត់បានល្អ។

ជាទូទៅ គ្រប់ស្ត្រីទាំងអស់មិនថាឡើយគាត់ផ្ទុកមេរោគអេដស៍ឬមិនមានផ្ទុកមេរោគអេដស៍នោះទេ ត្រូវបានលើកទឹកចិត្តឱ្យបំបៅកូនដោយដោះម្តាយតែមួយមុខគត់ក្នុងរយៈពេល៦ខែដំបូងនៃជីវិតកូន។ ការបំបៅដោះម្តាយតែមួយមុខគត់មានន័យថា កូនទទួលទឹកដោះម្តាយតែមួយមុខគត់។ កូនមិនត្រូវបានទទួលអាហារផ្សេងៗ ឬភេសជ្ជៈទេ រួមទាំងទឹកផង ក្នុងរយៈពេល៦ខែ នៃការបំបៅដោះកូន។

ស្ត្រីគ្មានផ្ទុកមេរោគអេដស៍និងស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ត្រូវបានលើកទឹកចិត្តឱ្យបន្តការបំបៅកូន ដោយដោះរហូតដល់២ឆ្នាំ រួមជាមួយនឹងការផ្តល់អាហារបន្ថែម។ គូស្វាមីភរិយាត្រូវបានលើកទឹកចិត្តឱ្យប្រើស្រោមអនាម័យនៅពេលកំពុងបំបៅកូនដោយដោះ។ ស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនត្រូវបានលើកទឹកចិត្តឱ្យធ្វើតេស្តឈាម រកមេរោគអេដស៍។

ស្ត្រីផ្ទុកមេរោគអេដស៍ ត្រូវបានលើកទឹកចិត្តឱ្យបំបៅកូនដោយដោះម្តាយតែមួយមុខគត់រយៈពេល៦ខែដំបូង បន្ទាប់មកត្រូវផ្តាច់ដោះកូនភ្លាម។ ត្រូវផ្តល់ពតិមានលំអិតដល់ស្ត្រីផ្ទុកមេរោគអេដស៍ពីជំរើសនៃការចិញ្ចឹមកូន។ ការចិញ្ចឹមកូនដោយទឹកដោះគោម្សៅ តាមរូបមន្តត្រូវបានជំរុញឱ្យប្រើប្រាស់តែក្នុងល័ក្ខខ័ណ្ឌ អាចទទួលយកបាន (Acceptable), ងាយស្រួលប្រើ (Feasible), អាចលៃលករកទិញបាន (Affordable), មានស្ថេរភាព (Sustainable), និង មានសុវត្ថិភាព (Safe), ។

| ការចិញ្ចឹមកូនដោយទឹកដោះសិប្បនិម្មិតត្រូវតែគោរពនូវល័ក្ខខ័ណ្ឌដូចតទៅ : | | |
|---|---|---|
| ➤ Acceptable | : | ការទទួលយកបាន ជាពិសេស ពីសង្គម ឬ ពីប្រពៃណី |
| ➤ Feasible | : | សំដៅដល់គ្រួសារនៃកុមារប្រឈមអាចយល់បាននិងធ្វើតាមការណែនាំក្នុងការរៀបចំទឹកដោះគោសំរាប់កូន និង អាចផ្តល់ឱ្យកូនបានយ៉ាងហោចណាស់៨ដងក្នុង១ថ្ងៃ |
| ➤ Affordable | : | សំដៅដល់គ្រួសារនៃកុមារប្រឈមអាចលៃលករកទិញទឹកដោះគោម្សៅតាមរូបមន្តសំរាប់កូនបានដោយមិនប៉ះពាល់ដល់តំរូវការសំរាប់ចិញ្ចឹមកូនដទៃទៀត។ មានន័យថាក្រៅពីម្សៅទឹក |

ដោះគោនៅមានអ្វីៗ ផ្សេងទៀតដែលគាត់ត្រូវការដូចជា ស្ករ មីក្រូសារជាតិបន្ថែម ទឹកស្អាត និងភ្លើងគ្រប់គ្រាន់សំរាប់ចំអិន ។

➤ Sustainable : សំដៅដល់ស្ថេរភាព, គ្រួសាររបស់កុមារប្រឈមអាចផ្គត់ផ្គង់ទឹកដោះគោម្សៅតាមរូបមន្តដល់កូនរបស់គាត់បានរយៈពេលយូរអង្វែង និងអាចជឿជាក់បាន ដើម្បីឆ្លើយតបទៅនឹងតំរូវការចំណីអាហាររបស់កុមារ ។

➤ Safe : សំដៅដល់សុវត្ថិភាព ។ គ្រួសាររបស់កុមារអាចទទួលបាននូវទឹកស្អាតសំរាប់លាយទឹកដោះគោ និង លាងសំភារៈផ្សេងៗដើម្បីឱ្យចំណីអាហារនិងសំភារៈប្រើប្រាស់ទាំងនោះស្អាតគ្មានមេរោគ ។ សុវត្ថិភាពក៏មានន័យផងដែរថា ម្ហូបអាហារដែលចំអិនហើយត្រូវទុកដាក់ឱ្យបានស្អាតត្រឹមត្រូវ ឬក៏ចំអិនអាហារម្តងសំរាប់១ពេល ។ បន្ថែមលើនេះទៀតសុវត្ថិភាពមានន័យថា នៅពេលដែលកូនមានបញ្ហាសុខភាពម្តាយអាចទទួលបាននូវសេវាថែទាំសុខភាព ដែលនៅជិតផ្ទះរបស់គាត់បាន ។

*Adapted from: UNICEF, 2004. "WHAT RELIGIOUS LEADERS CAN DO ABOUT HIV/AIDS: Action for Children and Young People".*

ចំពោះម្តាយដែលជ្រើសរើសការចិញ្ចឹមកូនដោយទឹកដោះម្សៅតាមរូបមន្ត ត្រូវពន្យល់គាត់ឱ្យបានច្បាស់លាស់ កុំឱ្យបំបៅកូនលាយជាមួយទឹកដោះម្តាយ ពីព្រោះការចិញ្ចឹមកូនបែបចំរុះនេះ បង្កើនការប្រឈមទៅនឹងការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន (Iliff PJ. et al., 2005) ។

បើសិនជាម្តាយជ្រើសរើសការបំបៅកូនដោយដោះតែមួយមុខគត់ ត្រូវផ្តល់ប្រឹក្សាដល់គាត់ពីរបៀបថែរក្សាដោះ ដើម្បីកាត់បន្ថយការប្រឈមនឹងការចំលងមេរោគអេដស៍ទៅកូននៅពេលកំពុងបំបៅដោះកូន ។ ការផ្តាច់ដោះកូនបានឆាប់រហ័សអាចកាត់បន្ថយការប្រឈមទៅនឹងការចំលងមេរោគអេដស៍ពម្តាយទៅកូន តាមរយៈការកាត់បន្ថយពេលវេលាដែលកុមារប្រឈមទៅនឹងមេរោគអេដស៍ដែលមាននៅក្នុងទឹកដោះម្តាយ ។ ដូច្នេះហើយបានជាគេណែនាំឱ្យម្តាយដែលមានផ្ទុកមេរោគអេដស៍បញ្ឈប់ការបំបៅដោះកូន នៅពេលដែលកូនមានអាយុ៦ខែ ។ មុនពេលផ្តាច់ដោះត្រូវផ្តល់ប្រឹក្សាដល់ម្តាយអំពីការផ្តល់អាហារូបត្ថម្ភបន្ថែមដល់កូន និង ពីរបៀបផ្តាច់ដោះកូននៅពេលដែលកូនមានអាយុ៦ខែ ។ អ្នកផ្តល់ប្រឹក្សាត្រូវផ្តល់ពត៌មានទាំងអស់នេះដល់ស្ត្រីនៅពេលដែលគាត់មកពិនិត្យផ្ទៃពោះ និងនៅក្រោយពេលសំរាល ។

## ៥.២ ការតាមដានសុខភាពទារក

កូនដែលកើតពីម្តាយដែលមានផ្ទុកមេរោគអេដស៍ ត្រូវបានបញ្ជូនឱ្យទៅទទួលសេវាតាមដានបន្តផ្នែកកុមាររហូតដល់អាយុ១៨ខែ នៅផ្នែកពិនិត្យជំងឺក្រៅដែលនៅជិតហើយដែលមានសេវា OI/ART ។ កូនដែលសំរាលពីម្តាយដែលមានផ្ទុកមេរោគអេដស៍ទាំងអស់ត្រូវធ្វើតេស្តឈាមរកមេរោគអេដស៍នៅពេលមានអាយុ១៨ខែ ដោយមានការយល់ព្រមពីម្តាយ ។ ការបង្ការជំងឺឱកាសនិយមក៏ត្រូវបានផ្តល់ជូនដល់កុមារប្រឈមទាំងអស់ផងដែរ ដោយមន្ទីរពេទ្យ

កុមារ ឬ គ្រឹះស្ថានសុខាភិបាលមូលដ្ឋានណាដែលមានសេវា OI/ART ។ យោងតាមគោលការណ៍ណែនាំជាតិស្តីពីការផ្តល់ឱសថប្រឆាំងមេរោគអេដស៍សំរាប់កុមារឱសថ កូទ្រីម៉ុកសាសុល (Cotrimoxazole), ត្រូវផ្តល់ឱ្យកុមារនៅអាយុ ៦អាទិត្យ និងបន្តឱ្យប្រើរហូតដល់ប្រាកដថាកុមារមិនមានឆ្លងមេរោគអេដស៍ពីម្តាយទេ ឬក៏គ្មានចេញរោគសញ្ញាអ្វីនៅពេលកុមារមានអាយុ១២ខែ។ សូមមើលតារាងខាងក្រោមសំរាប់ពិតមានលំអិតស្តីពីការផឹកឬលេប និងកំរិតថ្នាំ Cotrimoxazole ដែលត្រូវប្រើលើកុមារ។

## ឱសថ Cotrimoxazole

## ប្រើសំរាប់បង្ការជំងឺឱកាសនិយមចំពោះកុមារដែលប្រឈមឬមានផ្ទុកមេរោគអេដស៍

## (គ្រាប់ថ្នាំទំងន់ ៤៨០ម.ក, ស៊ីរ៉ូបចំណុះ ២៤០ម.ក/៥ម.ល)

| ទំងន់កុមារនិងកំរិតថ្នាំ Cotrimoxazole:ឱ្យម្តងក្នុង១ថ្ងៃ | ជំងឺឱកាសនិយមដែលត្រូវបង្ការ | ត្រូវប្រើនៅពេលណា | ឈប់ប្រើនៅពេលណា |
|---|---|---|---|
| 5-9kg: ½ គ្រាប់ or 5ml.<br><br>10-14kg: 1 គ្រាប់ or 10ml.<br><br>15-24kg: 1½ គ្រាប់ or 15ml.<br><br>>25kg: 2 គ្រាប់. | - ជំងឺរលាកសួតដោយមេរោគ Pneumocysti Carenie.<br>- ជំងឺរលាកស្រោមខួរក្បាល ដោយមេរោគ Toxoplasmosis.<br>- ជំងឺឆ្លងនានា | <u>ការបង្ការជាបឋម:</u><br>១- កុមារប្រឈមមានអាយុ៦អាទិត្យ<br>២- កុមារមានផ្ទុកមេរោគអេដស៍ និងមាន CD4<15%<br><br><u>ការបង្ការដំណាក់កាលទី២</u><br>បើសិនមានប្រវត្តិ PCP. | ១- បើសិនមេរោគអេដស៍អវិជ្ជមាន<br>២- កុមារមានអាយុ១២ខែ និងគ្មានចេញរោគសញ្ញាគ្លីនីក<br>៣- CD4>15% រាល់៦ខែម្តង រយៈពេល២ដង<br><u>ការបង្ការដំណាក់កាលទី២:</u>បន្តប្រើរហូតអស់មួយជីវិត |

*Source: NCHADS. 2004, National Guidelines for the use of Pediatric ARV.*

កុមារដែលប្រឈមនឹងការឆ្លងមេរោគអេដស៍ ក៏ត្រូវបានផ្តល់វ៉ាក់សាំងបង្ការដូចគ្នានឹងកុមារដទៃទៀតដែរ។ សូមអានគោលនយោបាយជាតិស្តីពីការផ្តល់ថ្នាំបង្ការរបស់កម្មវិធីចាក់ថ្នាំបង្ការជាតិ។

# ជំពូកទី ៦ : ផែនការគ្រួសារ

## ៦.១ ផែនការគ្រួសារនិងមេរោគអេដស៍

ការប្រើវិធីពន្យារកំណើតបែបសម័យឱ្យបានជាប់ជាប្រចាំនិងត្រឹមត្រូវអាចការពារមិនឱ្យស្ត្រីមានកូនដោយចៃដន្យ។ ការបង្ការកុំឱ្យមានគភ៌នេះ អាចជួយកាត់បន្ថយអត្រាស្លាប់ និងជំងឺរបស់ម្តាយ និងកូនបាន។ ស្រោមអនាម័យគឺជាវិធីពន្យារកំណើតបែបសម័យ មួយបែបដែលអាចជួយការពារជំងឺឆ្លងនានា ដូចជាជំងឺកាមរោគ និងជំងឺអេដស៍ជាដើម។ ការរារាំងមិនឱ្យស្ត្រីមកទទួលសេវាពន្យារកំណើតត្រូវហាមឃាត់ជាដាច់ខាត។

ដើម្បីឆ្លើយតបទៅនឹងតំរូវការដែលចេះតែកើនឡើងស្តីពីការទទួលពតិមានទទួលការផ្តល់ប្រឹក្សា និងសេវាផែនការគ្រួសារ, បុគ្គលិកសុខាភិបាលត្រូវរួមគ្នាធ្វើការដើម្បីផ្តល់សេវាពន្យារកំណើតដល់ស្ត្រីឱ្យបានគ្រប់គ្រាន់។ សេវាពន្យារកំណើតដែលផ្តល់ឱ្យស្ត្រីត្រូវតែជាសេវាដែលមានសុវត្ថិភាពប្រសិទ្ធិភាពអាចរកបាន និងអាចទទួលយកបាន។ វិធីពន្យារកំណើតមានវិធីថ្មីៗមួយចំនួនដែលបច្ចុប្បន្នកំពុងតែត្រូវបានយកមកប្រើប្រាស់។

ភាគីដែលពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមក្នុងការធ្វើឱ្យប្រសើរឡើងនូវពតិមានស្តីពីការពន្យារកំណើតដែលមានគុណភាពខ្ពស់សំរាប់ផ្តល់ឱ្យបុរស ស្ត្រី បុគ្គលដែលមិនទាន់រៀបការ និងយុវវ័យ ព្រមទាំងផ្តល់នូវវិធីពន្យារកំណើតសមស្របទាំងឡាយសំរាប់មនុស្សគ្រប់វ័យ។

ចំពោះស្ត្រីមានផ្ទុកមេរោគអេដស៍ដែលមិនចង់មានកូន ត្រូវផ្តល់ពតិមានដែលអាចជឿជាក់បាន និងផ្តល់ប្រឹក្សាដែលពោរពេញ ដោយការអាណិតស្រឡាញ់ដល់គាត់។ ពតិមានដែលត្រូវផ្តល់ឱ្យគាត់មានដូចជា ការប្រាប់ពីទីកន្លែងរំលូតកូនស្របច្បាប់ដល់ស្ត្រីដែលមិនចង់ទុកកូននិងពីពេលវេលាដែលស្ត្រីអាចធ្វើការរំលូតបាន។ ពតិមាន និងសេវាទាំងនេះត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ព្រោះវាជាផ្នែកមួយនៃការថែទាំសុខភាពបន្តពូជដែលគ្រប់ជ្រុងជ្រោយ។ នៅទីណាដែលមានសេវារំលូតកូនសេវានោះត្រូវតែប្រកបដោយសុវត្ថិភាព។ វាជាប្រការចាំបាច់ណាស់ដែលបុគ្គលិកសុខាភិបាលទាំងអស់ត្រូវមានសំភារៈវេជ្ជសាស្ត្រជំនាញបច្ចេកទេស និងពតិមានគ្រប់គ្រាន់ ដើម្បីផ្តល់សេវាព្យាបាលថែទាំឱ្យមានគុណភាពខ្ពស់។

ស្ត្រីដែលបានចូលរួមក្នុងកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវបានបញ្ជូនទៅសេវាពន្យារកំណើត និងត្រូវបានផ្តល់ប្រឹក្សាពីផលចំណេញ និងផលប៉ះពាល់នៃមធ្យោបាយពន្យារកំណើតនិមួយៗ ដែលកំពុងមានក្នុងសេវា។

## ៦.២ មធ្យោបាយផ្សេងៗនៃផែនការគ្រួសារ

ពត៌មានទាំងឡាយដែលទាក់ទងទៅនឹងផលចំណេញនិងផលប៉ះពាល់នៃមធ្យោបាយពន្យារកំណើតនិមួយៗ ត្រូវផ្តល់ឱ្យស្ត្រីគ្រប់រូបឱ្យបានពេញលេញ ដោយមិនគិតពីស្ថានភាពផ្ទុកមេរោគអេដស៍របស់គាត់ឡើយ។ ស្ត្រីដែលផ្ទុកមេរោគអេដស៍ត្រូវបានលើកទឹកចិត្តឱ្យប្រើស្រោមអនាម័យ ដើម្បីការពារជំងឺកាមរោគ ការពារការឆ្លងមេរោគអេដស៍ប្រភេទផ្សេងទៀត និង ការពារកុំឱ្យមានផ្ទៃពោះផងដែរ។ គ្រប់ស្ត្រីទាំងអស់ត្រូវបានបង្រៀនពីរបៀបប្រើស្រោមអនាម័យឱ្យបានត្រឹមត្រូវ និង ជំនាញក្នុងការចចារជាមួយដៃគូរួមភេទក្នុងការប្រើប្រាស់ស្រោមអនាម័យ។

មធ្យោបាយពន្យារកំណើតសមស្របសំរាប់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍ :

- ស្រោមអនាម័យសំរាប់បុរស និង ស្ត្រី
- ថ្នាំគ្រាប់ពន្យារកំណើត (បើសិនមិនទាន់ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ច្រើនមុខទេ)
- ថ្នាំចាក់ពន្យារកំណើត
- ការវះចង
- ការពន្យារកំណើតដោយប្រើ Implants (ការដាក់កងនៅដើមដៃ)

ការប្រើសារជាតិគីមីសំលាប់កោសិកាបន្តពូជឈ្មោលអាចបណ្តាលឱ្យក្រហល់ក្រហាយទ្វារមាស និងធ្វើឱ្យរលាកភ្នាសនៃកោសិកាទ្វារមាសផងដែរ ។ ហេតុដូច្នេះហើយ មធ្យោបាយនេះមិនត្រូវបានណែនាំឱ្យប្រើចំពោះស្ត្រីដែលមានផ្ទុកមេរោគអេដស៍ទេ ព្រោះថាវាអាចបង្កើនគ្រោះប្រឈមនឹងការចំលងមេរោគអេដស៍ទៅដៃគូរបស់គាត់។ ការដាក់កងទៅក្នុងស្បូនក៏មិនត្រូវបានណែនាំឱ្យប្រើដែរ ចំពោះស្ត្រីដែលមានផ្ទុកមេរោគអេដស៍ពីព្រោះវាងាយប្រឈមនឹងជំងឺរលាកអាងត្រគាក និងងាយធ្វើឱ្យបាត់បង់ឈាមច្រើននៅពេលមានឈាមរដូវ។

# ជំពូកទី ៧ : ការទទួលយកសេវាថែទាំបន្ត

## ៧.១_ ធ្វើសមាហរណកម្ម កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន នៅក្នុងប្រព័ន្ធសុខាភិបាលដែលមានស្រាប់

កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនប្រើប្រាស់ប្រព័ន្ធសុខាភិបាលដែលមានស្រាប់ ដើម្បីបង្កើនគុណភាពនៃសេវា ថែទាំសុខភាពដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើសេវាសុខភាពមាតានិងទារក។ ដើម្បីឱ្យកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនទទួលបានជោគជ័យ យើងត្រូវមានបណ្តាញទំនាក់ទំនង និងសំរបសំរួលឱ្យរឹងមាំរវាងកម្មវិធីផ្សេងៗដែលកំពុងដំណើរការ ដូចជា កម្មវិធីពន្យារកំណើតកម្មវិធីអាហាររូបត្ថម្ភ និង កម្មវិធីជំងឺឆ្លងនានា (រួមមានជំងឺគ្រុនចាញ់ របេង និង ជំងឺអេដស៍ជាដើម)។

កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននឹងអនុវត្តជាបន្តនៅតាមមណ្ឌលសុខភាព និង មន្ទីរពេទ្យបង្អែកនានាដែលមានស្រាប់។ មន្ត្រី-បុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាល និងមានបទពិសោធន៍ ហើយដែលកំពុងតែបំរើការនៅក្នុងប្រព័ន្ធសុខាភិបាល ត្រូវបានជ្រើសរើសឱ្យបំរើការងារក្នុងកម្មវិធីនេះ។

## ៧.២ យន្តការបញ្ជូន

ដើម្បីធានាបាននូវការថែទាំអ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍មួយដ៏ល្អ វាជាប្រការចាំបាច់ណាស់ដែលត្រូវបង្កើតឱ្យមានយន្តការបញ្ជូនដ៏រឹងមាំនិងមានប្រសិទ្ធិភាពនៅតាមថ្នាក់ស្រុកប្រតិបត្តិ ផ្សាភ្ជាប់ទំនាក់ទំនងរវាងស្ថាប័នសុខភាពនានាដូចជា សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ សេវាផ្តល់ការព្យាបាលជំងឺឱកាសនិយម-ព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍ (OI/ART) សេវាផ្តល់ការព្យាបាលជំងឺរបេង/អេដស៍ កម្មវិធីកំចាត់ជំងឺគ្រុនចាញ់ ក្រុមថែទាំអ្នកជំងឺអេដស៍តាមផ្ទះ និងជាមួយអង្គការគាំទ្រនានា។ យន្តការបញ្ជូនត្រូវបានរៀបចំឡើងដោយគណៈកម្មការសំរបសំរួលការថែទាំបន្តនៃស្រុកប្រតិបត្តិនិមួយៗ។ គ្រប់ស្ត្រីមានគិភដែលមានផ្ទុកមេរោគអេដស៍ដែលយើងរកឃើញនឹងទទួលបាននូវពត៌មាន និងត្រូវបានធ្វើការបញ្ជូនទៅទទួលសេវាថែទាំបន្ត និងសេវាគាំទ្រដទៃទៀតដែលមាននៅក្នុងតំបន់ដែលគាត់រស់នៅ។ ទំរង់បែបបទបញ្ជូនដែលផលិតដោយមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារកនៃក្រសួងសុខាភិបាលត្រូវប្រើប្រាស់ដើម្បីបញ្ជូនស្ត្រីមានគិភពីកន្លែងពិនិត្យផ្ទៃពោះទៅផ្នែកពិនិត្យជំងឺក្រៅដែលមានសេវាព្យាបាលជំងឺឱកាសនិយម-សេវាព្យាបាលដោយប្រើថ្នាំប្រឆាំងមេរោគអេដស៍ ដែលនៅជិតបំផុត (សូមមើលឧបសម្ព័ន្ធ C) ឬ សេវាដទៃទៀត។ ផ្នែកពិនិត្យជំងឺក្រៅត្រូវប្រើប័ណ្ណបញ្ជូនដែលផលិតដោយមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ដើម្បីបញ្ជូនស្ត្រីមានគិភពីកន្លែងពិនិត្យជំងឺក្រៅទៅកាន់សេវាពិនិត្យផ្ទៃពោះ និង ផ្នែកសម្ភពដែលមានផ្តល់ឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលង (សូមមើលឧបសម្ព័ន្ធ D)។

មេរោគគ្រុនចាញ់ដែលនៅនឹងសុក រួមចំណែកក្នុងការធ្វើឱ្យអត្រានៃការចំលងមេរោគអេដស៍ពីម្តាយទៅកូនកាន់តែខ្ពស់។ ដូច្នេះ គ្រប់ស្ត្រីមានគភ៌ដែលមានផ្ទុកមេរោគអេដស៍ទាំងអស់ដែលរស់នៅក្នុងតំបន់គ្រុនចាញ់ គួរតែបញ្ជូនទៅទទួលសេវានៃកម្មវិធីកំចាត់ជំងឺគ្រុនចាញ់ដែលនៅជិតបំផុត ហើយគួរជំរុញអោយស្ត្រីសំរាកក្នុងមុងផងដែរ។

## ៧.៣ គណៈកម្មការសំរបសំរួលការថែទាំបន្ត

អ្នកសំរបសំរួលកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនថ្នាក់ស្រុកប្រតិបត្តិគួរតែជាសមាជិកបង្គោលនៃគណៈកម្មការសំរបសំរួលការថែទាំបន្ត។ ដូចដែលមានចែងនៅក្នុងគំរោងថែទាំបន្ត គណៈកម្មការសំរបសំរួលការថែទាំបន្តនឹងធានាឱ្យបានថាគ្រប់ដៃគូទាំងអស់នៅថ្នាក់ស្រុកប្រតិបត្តិនឹងធ្វើការជាមួយគ្នាដើម្បីប្រើប្រាស់ធនធានអោយបានប្រសើរបំផុត។ គណៈកម្មការនឹងធ្វើការកំណត់ពីតំរូវការ ចន្លោះខ្វះខាត និង តំបន់សហប្រតិបត្តិការនិងសំរបសំរួលក្នុងចំណោមដៃគូដែលពាក់ព័ន្ធទៅនឹងការថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍នៅក្នុងស្រុករបស់ខ្លួន។ គណៈកម្មការនេះនឹងជួយកំនត់នូវយន្តការបញ្ជូនសំរាប់អ្នកជំងឺអេដស៍ រវាងស្ថាប័នថែទាំជាមួយនឹងក្រុមថែទាំតាមផ្ទះ និងតាមសហគមន៍។ គណៈកម្មការក៏បានផ្តល់ផងដែរនូវវេទិកាប្រជុំជាប្រចាំមួយសំរាប់ការពិភាក្សាបញ្ហាដែលទាក់ទងទៅនឹងការថែទាំអ្នកជំងឺអេដស៍បន្ត”។

យោងទៅតាមគំរោងថែទាំអ្នកជំងឺអេដស៍បន្ត ខេត្តដែលមានស្រុកប្រតិបត្តិតែមួយ ការសំរបសំរួលសកម្មភាពត្រូវសំរេចដោយគណៈកម្មការសំរបសំរួលថ្នាក់ខេត្ត។ សំរាប់ខេត្តដែលមានស្រុកប្រតិបត្តិច្រើន ហើយដែលមានគណៈកម្មការសំរបសំរួលនៅតាមមូលដ្ឋានស្រុក ការទំនាក់ទំនងនានាពីស្រុកប្រតិបត្តិមួយទៅស្រុកប្រតិបត្តិមួយ និង ពីស្រុកទៅខេត្តត្រូវតែធ្វើការពិភាក្សាជាមុន។

# ជំពូកទី ៨ : ការអភិបាល និង ការត្រួតពិនិត្យគុណភាព

## ៨.១ ការអភិបាល

ការអភិបាល គឺជាផ្នែកមួយដ៏សំខាន់ក្នុងការតាមដានគុណភាពនៃកម្មវិធីហើយអាចផ្ដល់នូវព័តមានត្រឡប់ដ៏មានសារៈប្រយោជន៍ ជូនទៅមូលដ្ឋានវិញ ក្នុងគោលដៅធ្វើអោយកម្មវិធីកាន់តែល្អប្រសើរឡើង។ ដើម្បីធានាគុណភាពនៃកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្ដាយទៅកូន ការអភិបាលត្រូវធ្វើទាំងនៅឯមូលដ្ឋាន ថ្នាក់ខេត្ត និង ថ្នាក់ជាតិ។ ការចុះអភិបាលមិនត្រឹមតែជួយសំរាលនូវបញ្ហាដែលកើតមានឡើងនោះទេ ថែមទាំងអាចរកឃើញនូវចំនុចខ្លាំង និងជោគជ័យសំរាប់កម្មវិធីថែមទៀតផង។ អ្នកចុះអភិបាលត្រូវតែជាអ្នកផ្ដល់ការគាំទ្រ និងផ្ដល់ដំបូន្មានជាវិជ្ជមាន និងជាអ្នកជំរុញលើកទឹកចិត្តបុគ្គលិក នៅពេលដែលចាំបាច់។ បញ្ហាជាគន្លឹះសំរាប់ការអភិបាលមាន :

១. ជួយសំរួលគាំទ្រដល់បុគ្គលិកដែលកំពុងបំពេញការងារ ដើម្បីធ្វើឱ្យបរិយាកាសមានភាពល្អប្រសើរ

២. ធានាថាការប្រឹក្សាយោបល់ពេញលេញត្រូវបានផ្ដល់ដល់ស្ត្រីព្រមទាំងដៃគូរបស់គាត់

៣. ធានាការលាក់ការសំងាត់នៃលទ្ធផលតេស្ដ

៤. ធានាថាការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍មានគ្រប់គ្រាន់ និង ស្ត្រីបានប្រើឱសថត្រឹមត្រូវ

៥. ធានាថាម្ដាយ និងកូន ត្រូវបានបញ្ជូនទៅបណ្ដាញថែទាំដែលកំពុងមានដំណើរការ

៦. បង្កើនជំនាញដល់បុគ្គលិក

៧. សំរាលបញ្ហា និងរកដំណោះស្រាយយ៉ាងមានប្រសិទ្ធិភាព

មណ្ឌលបង្ការការចំលងមេរោគអេដស៍ពីម្ដាយទៅកូន ត្រូវធានានូវការផ្គត់ផ្គង់សំភារៈឱ្យបានគ្រប់គ្រាន់ និងទាន់ពេលដល់បុគ្គលិក និងផ្ដល់សេវាពិនិត្យផ្ទៃពោះឱ្យបានសមស្របដល់ស្ត្រីមានគភ៌ទាំងឡាយដែលមកទទួលសេវា។ បញ្ជីផ្ទៀងផ្ទាត់សំរាប់តាមដាន ដែលបានផលិតដោយមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក នឹងត្រូវបានប្រើប្រាស់ដោយអ្នកសំរបសំរួលកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្ដាយទៅកូននៅថ្នាក់ស្រុកប្រតិបត្តិ (សូមមើលឧបសម្ព័ន្ធ E) ដើម្បីជាជំនួយដល់ការពិនិត្យតាមដានសេវា និងការផ្គត់ផ្គង់រៀងរាល់ខែ។ អ្នកសំរបសំរួលថ្នាក់ស្រុកត្រូវបំពេញបញ្ជីផ្ទៀងផ្ទាត់នេះ១ខែម្ដងដើម្បីផ្ញើរមកអ្នកសំរបសំរួលកម្មវិធីខេត្ត។

អ្នកសំរបសំរួលកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្ដាយទៅកូនថ្នាក់ខេត្ត និង/ឬក៏អ្នកគ្រប់គ្រងកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្ដាយទៅកូនខេត្ត ត្រូវចុះអភិបាលមណ្ឌលនិមួយៗរៀងរាល់៣ខែម្ដង។ បុគ្គលិកមកពីថ្នាក់ជាតិនឹងធ្វើការចុះអភិបាលជាមួយថ្នាក់ខេត្តរៀងរាល់៦ខែម្ដង។ ក្នុងករណីចាំបាច់ដើម្បីឆ្លើយតបទៅនឹងតំរូវការបន្ទាន់ ថ្នាក់ជាតិនឹងចុះធ្វើអភិបាល ដោយមិនរង់ចាំពេលវេលាដែលបានកំណត់ទេ។ បញ្ជីផ្ទៀងផ្ទាត់សំរាប់ការចុះអភិបាលដែលផលិតដោយមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក (សូមមើលឧបសម្ព័ន្ធ F) ត្រូវប្រើប្រាស់និងបំពេញ

នៅរាល់ពេលចុះអភិបាលម្តងៗ។ រាល់បញ្ជីផ្ទៀងផ្ទាត់ដែលបានបំពេញរួចហើយ ត្រូវផ្ញើមកលេខាធិការដ្ឋាននៃកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។

ប្រធានកម្មវិធីឬអ្នកសំរបសំរួលកម្មវិធីថ្នាក់ខេត្ត និង មន្ត្រី-បុគ្គលិកនៃកម្មវិធីថ្នាក់ជាតិត្រូវផ្តល់ពត៌មានត្រឡប់ឱ្យទៅមណ្ឌលបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន និងទៅប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាប់ពីការចុះអភិបាលរួច។ ពត៌មានត្រឡប់មិនត្រូវលើកឡើងតែពីគុណវិបត្តិប៉ុណ្ណោះទេ តែត្រូវលើកឡើងពីចំណុចល្អនៃការងារផងដែរ។

## ៨.២ ការត្រួតពិនិត្យគុណភាព

រាល់ការត្រួតពិនិត្យគុណភាពតេស្តសំរាប់រកមេរោគអេដស៍និងមេរោគស្វាយ នឹងត្រូវបានរៀបចំ និងអនុវត្តន៍ដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ។

# ជំពូកទី ៩ : ការតាមដាននិងវាយតំលៃ

## ៩.១ ការប្រមូលទិន្នន័យ និង របាយការណ៍

មណ្ឌលបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននិមួយៗ ទទួលខុសត្រូវលើការប្រមូលទិន្នន័យប្រចាំខែសំរាប់បញ្ជូនមកអ្នកសំរបសំរួលថ្នាក់ស្រុក។ អ្នកសំរបសំរួលថ្នាក់ស្រុកប្រមូលទិន្នន័យពីគ្រប់មណ្ឌល រួចបញ្ជូនមកថ្នាក់ខេត្តរៀងរាល់ខែ។ អ្នកសំរបសំរួលថ្នាក់ខេត្តទទួលខុសត្រូវលើការប្រមូលផ្តុំទិន្នន័យពីគ្រប់ស្រុក និងបញ្ជូនមកលេខាធិការដ្ឋានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារករៀងរាល់ខែ។ រាល់របាយការណ៍ដែលបញ្ជូនមកការិយាល័យកណ្តាលមិនគួរលើសពី ១ សប្តាហ៍នៃដើមខែបន្ទាប់ទេ។ មណ្ឌលបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននិមួយៗ អាចប្រមូលពតិមានបន្ថែមផ្សេងទៀតទៅតាមការចាំបាច់របស់ខ្លួន ។ ក៏ប៉ុន្តែមណ្ឌលទាំងអស់ត្រូវតែបំពេញទំរង់ទិន្នន័យប្រចាំខែ ដែលផលិតដោយលេខាធិការដ្ឋានកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក។ ទិន្នន័យដែលត្រូវប្រមូលមាន :

**ស្ត្រីមានគភ៌នៅសេវាពិនិត្យផ្ទៃពោះ និងផ្តល់ប្រឹក្សាធ្វើតេស្តឈាម**

១. ចំនួនស្ត្រីមកពិនិត្យផ្ទៃពោះទាំងអស់

២. ចំនួនស្ត្រីមកពិនិត្យផ្ទៃពោះលើកទីមួយ

៣. ចំនួនស្ត្រីដែលបានទទួលការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាម

៤. ចំនួនដៃគូដែលបានទទួលការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាម

៥. ចំនួនស្ត្រីដែលពិគ្រោះជាមួយដៃគូមុនពេលធ្វើតេស្តឈាម

៦. ចំនួនស្ត្រីស្ម័គ្រចិត្តធ្វើតេស្តឈាម

៧. ចំនួនដៃគូស្ម័គ្រចិត្តធ្វើតេស្តឈាម

៨. ចំនួនស្ត្រីបានទទួលការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាម

៩. ចំនួនដៃគូបានទទួលការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាម

១០. ចំនួនស្ត្រីវិជ្ជមានមេរោគអេដស៍

១១. ចំនួនដៃគូវិជ្ជមានមេរោគអេដស៍

១២. ចំនួនស្ត្រីស្ម័គ្រចិត្តធ្វើតេស្តលើកទី២

១៣. ចំនួនដៃគូស្ម័គ្រចិត្តធ្វើតេស្តលើកទី២

១៤. ចំនួនស្ត្រីវិជ្ជមានមេរោគអេដស៍លើកទី២

១៥. ចំនួនដៃគូវិជ្ជមានមេរោគអេដស៍លើកទី២

១៦. ចំនួនស្ត្រីផ្ទុកមេរោគអេដស៍បញ្ជូនមកពី...

១៧. ចំនួនស្ត្រីផ្ទុកមេរោគអេដស៍បញ្ជូនទៅសេវា CoC/OI/ART

១៨. ចំនួនដៃគូផ្ទុកមេរោគអេដស៍បញ្ជូនទៅសេវា CoC/OI/ART

១៩. ចំនួនស្ត្រីចាប់ផ្តើមប្រើ ZDV

២០. ចំនួនស្ត្រីកំពុងព្យាបាលដោយ HAART

### ផ្នែកសំរាល

២១. ចំនួនស្ត្រីសំរាលកូនសរុបក្នុង១ខែ

២២. ចំនួនស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន

២៣. ចំនួនស្ត្រីអវិជ្ជមានមេរោគអេដស៍

២៤. ចំនួនស្ត្រីវិជ្ជមានមេរោគអេដស៍

### ម្តាយៗរបបព្យាបាល/បង្ការដោយឱសថប្រឆាំងមេរោគអេដស៍

២៥. ចំនួនស្ត្រីបានទទួល HAART> ៤អាទិត្យ

២៦. ចំនួនស្ត្រីបានទទួល HAART<៤អាទិត្យ

២៧. ចំនួនស្ត្រីបានទទួលឱសថបង្ការ ZDV>៤អាទិត្យ

២៨. ចំនួនស្ត្រីបានទទួល ZDV<៤អាទិត្យ

២៩. ចំនួនស្ត្រីដែលបានទទួលZDV ជាមួយNVP នៅពេលឈឺពោះសំរាល

៣០. ចំនួនស្ត្រីដែលមិនបានទទួលឱសថបង្ការនៅពេលឈឺពោះសំរាល

### កូនសំរាលពីម្តាយដែលមានផ្ទុកមេរោគអេដស៍

៣១. ចំនួនកូនបានទទួល NVP ១ដូសនិង ZDV១អាទិត្យក្រោយសំរាល

៣២. ចំនួនកូនបានទទួល NVP ១ដូសនិង ZDV ៤អាទិត្យក្រោយសំរាល

៣៣. ចំនួនកូនចិញ្ចឹមដោយដោះម្តាយ

៣៤. ចំនួនកូនចិញ្ចឹមដោយទឹកដោះសិប្បនិម្មិត

### ការតាមដានសុខភាពកុមារ

៣៥. ចំនួនកុមារប្រឈមដែលត្រឡប់មកធ្វើការតាមដាន

៣៦. ចំនួនកុមារប្រឈមបញ្ជូនទៅសេវាថែទាំកុមារ

៣៧. ចំនួនកុមារប្រឈមដែលបានទទួលឱសថបង្ការCotrimoxazole

៣៨. ចំនួនកុមារដែលបានធ្វើតេស្តរកមេរោគអេដស៍នៅអាយុ១៨ខែ

៣៩. ចំនួនក្មេងប្រុសវិជ្ជមានមេរោគអេដស៍ នៅអាយុ១៨ខែ

៤០. ចំនួនក្មេងស្រីវិជ្ជមានមេរោគអេដស៍នៅអាយុ១៨ខែ

៤១. ចំនួនកុមារផ្ទុកមេរោគអេដស៍ទទួល ART

## ៩.២ ការតាមដានជាទៀងទាត់

កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនត្រូវពិនិត្យតាមដាននិងអភិបាល ដោយប្រធាននិងអ្នកសំរបសំរួលកម្មវិធីបង្ការ ការចំលងមេរោគអេដស៍ពីម្តាយទៅកូន (សូមមើលជំពូកទី៨)។ ទិន្នន័យដែលប្រមូលបានរៀងរាល់ខែ នឹងត្រូវបានពិនិត្យឡើងវិញ និងប្រើប្រាស់ដោយក្រុមការងារទុកជាឧបករណ៍តាមដានសំរាប់ទីតាំងបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។

តារាងសុច្ចនករខាងក្រោមនេះ បានរៀបចំឡើងដើម្បីតាមដានសមិទ្ធផលនៃកម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។ សុច្ចនករទាំងនេះអាចយកមកគណនាដោយប្រើរបាយការណ៍ប្រចាំខែដែលបញ្ជូនពីថ្នាក់ខេត្ត ព្រមទាំងរបាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក និង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគផងដែរ។ បន្ថែមលើការប្រើប្រាស់ក្នុងរង្វង់កម្មវិធី ទិន្នន័យនេះនឹងត្រូវរាយការណ៍ទៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ និង ទៅក្រសួងសុខាភិបាល។ សុច្ចនករដែលត្រូវប្រើប្រាស់សំរាប់ថ្នាក់ជាតិមានដូចតទៅ :

| សុច្ចនករនៃកម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន | |
|---|---|
| **សុច្ចនករទី១** | ភាគរយនៃស្រុកប្រតិបត្តិដែលមានកញ្ចប់សកម្មភាពអប្បបរិមានៃសេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនយ៉ាងហោចណាស់មួយ។ |
| ប្រភេទ | OUTCOMEលទ្ធផលរំពឹងទុក |
| និយមន័យ | សុច្ចនករនេះវាស់អត្រាគ្របដណ្តប់នៃកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននៅទូទាំងប្រទេស។គេវាស់ភាគរយនៃស្រុកប្រតិបត្តិដែលមានកញ្ចប់សកម្មភាពអប្បបរិមានៃសេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនយ៉ាងតិចមួយ។ កញ្ចប់សកម្មភាពនៃសេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនមាន:<br>➢ ការផ្តល់ប្រឹក្សានឹងធ្វើតេស្តដល់ស្ត្រីមានផ្ទៃពោះ<br>➢ ការប្រើឱសថបង្ការប្រឆាំងមេរោគអេដស៍ដើម្បីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន<br>➢ ការផ្តល់ប្រឹក្សានិងគាំទ្រដល់ការចិញ្ចឹមកូនឱ្យមានសុវត្ថិភាព<br>➢ ការផ្តល់ប្រឹក្សាពីផែនការគ្រួសារ ឬបញ្ជូន |
| ភាគយក | ចំនួនស្រុកប្រតិបត្តិដែលយ៉ាងហោចណាស់មានសេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនមួយកន្លែង។ |
| ភាគបែង | ចំនួនស្រុកប្រតិបត្តិដែលកំពុងដំណើរការទាំងអស់។ |
| វិធីតាមដាននិងវាយតំលៃ | របាយការណ៍ |

| | |
|---|---|
| ពេលវេលា | ១ត្រីមាសម្តង |
| ប្រភព | របាយការណ៍ពីលេខាធិការដ្ឋាននៃកម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន |
| កំណត់ចំណាំ | សុច្ចនករគ្របដណ្តប់ទី១របស់ GFATM ; PEPFAR. |

| **សុច្ចនករទី២** | ភាគរយនៃស្ត្រីមកពិនិត្យផ្ទៃពោះលើកទី១ ដែលបានស្ម័គ្រចិត្តធ្វើតេស្តឈាមរកមេរោគអេដស៍ ។ |
|---|---|
| ប្រភេទ | OUTCOMEលទ្ធផលរំពឹងទុក |
| និយមន័យ | សុច្ចនករនេះវាស់អត្រាស្ត្រីមានគិភដែលចូលរួមធ្វើតេស្តឈាម ។ គេវាស់ភាគរយនៃស្ត្រីមានគិភដែលមកទទួលសេវាពិនិត្យផ្ទៃពោះលើកទី ១ នៅមណ្ឌលសុខភាពចំណុច និងបានស្ម័គ្រចិត្តធ្វើតេស្តឈាមរកមេរោគអេដស៍ ។ |
| ភាគយក | ចំនួនស្ត្រីមានគិភទាំងអស់ដែលស្ម័គ្រចិត្តធ្វើតេស្តឈាមរកមេរោគអេដស៍ ។ |
| ភាគបែង | ចំនួនស្ត្រីមានគិភទាំងអស់ដែលមកមណ្ឌលសុខភាពចំណុចបានមកពិនិត្យផ្ទៃពោះលើកទី១ ។ |
| វិធីតាមដាននិងវាយតំលៃ | របាយការណ៍ប្រចាំខែពីថ្នាក់ខេត្ត |
| ពេលវេលា | ១ត្រីមាសម្តង |
| ប្រភព | របាយការណ៍ពីលេខាធិការដ្ឋាននៃកម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន |
| កំណត់ចំណាំ | |

| **សុច្ចនករទី៣** | ភាគរយនៃស្ត្រីដែលមកពិនិត្យផ្ទៃពោះលើកទី១បានទទួលការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាម ។ |
|---|---|
| ប្រភេទ | OUTCOMEលទ្ធផលរំពឹងទុក |
| និយមន័យ | សុច្ចនករនេះវាស់អត្រាចូលរួមរបស់ស្ត្រីដែលមកពិនិត្យផ្ទៃពោះលើកទី១ហើយបានស្ម័គ្រចិត្តធ្វើតេស្តឈាមនិងបានវិលត្រឡប់មកទទួលលទ្ធផលតេស្តវិញ ។ គេវាស់ភាគរយនៃស្ត្រីដែលមកទទួលលទ្ធផលតេស្តនិងបានទទួលការប្រឹក្សាក្រោយតេស្តនៅមណ្ឌលសុខភាពចំណុច ។ |
| ភាគយក | ចំនួនស្ត្រីមានគិភទាំងអស់ដែលមកទទួលលទ្ធផលតេស្ត និងបានទទួលការផ្តល់ប្រឹក្សាសមស្រប ។ |
| ភាគបែង | ចំនួនស្ត្រីមានគិភទាំងអស់ដែលមកពិនិត្យផ្ទៃពោះលើកទី១នៅមណ្ឌលសុខភាពចំណុច ។ |
| វិធីតាមដាននិងវាយតំលៃ | របាយការណ៍ប្រចាំខែពីថ្នាក់ខេត្ត |
| ពេលវេលា | ១ត្រីមាសម្តង |
| ប្រភព | របាយការណ៍ពីលេខាធិការដ្ឋាននៃកម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន |
| កំណត់ចំណាំ | សុច្ចនករគ្របដណ្តប់ទី២របស់ GFATM ; PEPFAR. |

| | |
|---|---|
| **សូចនាករទី៤** | ភាគរយនៃបុរសជាប្តី/ដៃគូបានទទួលការផ្តល់ប្រឹក្សាក្រោយតេស្តតាមរយៈកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។ |
| ប្រភេទ | OUTCOME លទ្ធផលរំពឹង |
| និយមន័យ | សូចនាករនេះវាស់អត្រាចូលរួមរបស់បុរស។ គេវាស់ភាគរយនៃបុរសជាប្តី/ដៃគូមកទទួលលទ្ធផលតេស្តនិងបានទទួលការផ្តល់ប្រឹក្សាក្រោយតេស្តឈាមតាមរយៈកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។ |
| ភាគយក | ចំនួនបុរសជាប្តី /ដៃគូដែលបានទទួលការផ្តល់ប្រឹក្សាក្រោយតេស្ត |
| ភាគបែង | ចំនួនស្ត្រីមានផ្ទៃពោះទាំងអស់ដែលមកមណ្ឌលសុខភាពចំណុចពិនិត្យផ្ទៃពោះលើកទី១ |
| វិធីតាមដាននិងវាយតំលៃ | របាយការណ៍ប្រចាំខែពីថ្នាក់ខេត្ត |
| ពេលវេលា | ១ត្រីមាសម្តង |
| ប្រភព | របាយការណ៍ពីលេខាធិការនៃកម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន |
| កំណត់ចំណាំ | |

| | |
|---|---|
| **សូចនាករទី៥** | ភាគរយនៃកូនដែលសំរាលពីម្តាយដែលមានផ្ទុកមេរោគអេដស៍ (ដែលបានចូលរួមក្នុងកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន) បានទទួលឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនបានពេញលេញ។ |
| ប្រភេទ | OUTCOME លទ្ធផលរំពឹងទុក |
| និយមន័យ | សូចនាករនេះវាស់អត្រានៃកុមារដែលសំរាលពីម្តាយដែលមានផ្ទុកមេរោគអេដស៍ (ម្តាយបានចូលរួមក្នុងកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន) បានទទួលឱសថប្រឆាំងមេរោគអេដស៍ ដើម្បីបន្ថយគ្រោះចំលងមេរោគអេដស៍ពីម្តាយទៅកូន។ |
| ភាគយក | ចំនួនកូនទាំងអស់ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលង។ |
| ភាគបែង | ចំនួនម្តាយផ្ទុកមេរោគអេដស៍ទាំងអស់ដែលបង្ហាញអត្តសញ្ញាណរបស់ខ្លួននៅពេលសំរាល។ |
| វិធីតាមដាននិងវាយតំលៃ | របាយការណ៍ប្រចាំខែពីថ្នាក់ខេត្ត |
| ពេលវេលា | ១ត្រីមាសម្តង |
| ប្រភព | របាយការណ៍ពីការិយាល័យនៃកម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន |
| កំណត់ចំណាំ | សូចនាករគ្របដណ្តប់ទីពាររបស់ GFATM |

| **សូចនករទី៦** | ចំនួន និង ភាគរយនៃកូនសំរាលពីម្តាយដែលមានផ្ទុកមេរោគអេដស៍ បានទទួលឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលងក្រោយពេលសំរាល និងមានផ្ទុកមេរោគអេដស៍នៅអាយុ១៨ខែ។ |
|---|---|
| ប្រភេទ | IMPACT គោលដៅដែលសំរេចបាន |
| និយមន័យ | សូចនករនេះវាស់អត្រានៃការចំលងមេរោគអេដស៍ពីម្តាយទៅកូនក្រោយពីបានប្រើឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលង ទាំងម្តាយទាំងកូន។ |
| ភាគយក | ចំនួនកូនសំរាលពីម្តាយផ្ទុកមេរោគអេដស៍ទាំងអស់ ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលងក្រោយសំរាល និងមានតេស្តឈាមវិជ្ជមាននៅអាយុ ១៨ខែ។ |
| ភាគបែង | ចំនួនកូនសំរាលពីម្តាយផ្ទុកមេរោគអេដស៍ទាំងអស់ ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលងក្រោយសំរាល និងបានធ្វើតេស្តឈាមរកមេរោគអេដស៍នៅអាយុ១៨ខែ។ |
| វិធីតាមដាននិងវាយតំលៃ | របាយការណ៍ប្រចាំខែពីថ្នាក់ខេត្ត និង ឬ ការអង្កេតពីក្រៅ |
| ពេលវេលា | ១ឆ្នាំម្តង |
| ប្រភព | របាយការណ៍ពីលេខាធិការដ្ឋាននៃកម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន |
| កំណត់ចំណាំ | សូចនករគោលដៅរបស់ UNGASS AND GFATM |

| **សូចនករទី៧** | ចំនួនបុគ្គលិកសុខាភិបាល អ្នកផ្តល់ប្រឹក្សា និង អ្នកផ្ទុកមេរោគអេដស៍បានទទួលការបណ្តុះបណ្តាលស្តីពីកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។ |
|---|---|
| ប្រភេទ | OUTPUTទិន្នផល |
| និយមន័យ | សូចនករនេះវាស់ពីការបណ្តុះបណ្តាលសមត្ថភាព។ គេវាស់ចំនួនបុគ្គលិកសុខាភិបាល អ្នកផ្តល់ប្រឹក្សា និងអ្នកផ្ទុកមេរោគអេដស៍ ដែលបានទទួលការបណ្តុះបណ្តាលពីកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។ |
| វិធីតាមដាននិងវាយតំលៃ | របាយការណ៍បណ្តុះបណ្តាល |
| ពេលវេលា | ១ឆ្នាំម្តង |
| ប្រភព | របាយការណ៍ពីការិយាល័យនៃកម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន |
| កំណត់ចំណាំ | សូចនករ GFATM #2; PEPFAR |

## ៩.៣ ការវាយតំលៃ

មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងក្រសួងសុខាភិបាល នឹងធ្វើការវាយតំលៃកម្មវិធីជាតិបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនរៀងរាលឆ្នាំ។ ការវាយតំលៃកម្មវិធីនេះ ផ្អែកទៅលើទិន្នន័យដែលមានស្រាប់ របាយការណ៍ និងបទពិសោធន៍កន្លងមក។

# ជំពូកទី ១០ : ការត្រៀមលក្ខណៈសំរាប់ដំណើរការកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននៅមណ្ឌលថ្មី

## ១០.១ ការជ្រើសរើសមណ្ឌល

គ្រឹះស្ថានសុខាភិបាលដែលនឹងដំណើរការកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនតំរូវឱ្យមានការកំណត់ និងការជ្រើសរើសដោយមន្ទីរសុខាភិបាលខេត្ត និងប្រធានស្រុកប្រតិបត្តិផ្ទាល់។ មណ្ឌលបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននិមួយៗត្រូវមានលក្ខណៈដូចតទៅនេះ :

- សមត្ថភាពផ្តល់សេវាថែទាំមុន និងក្រោយសំរាលរួមនឹងសេវាពន្យារកំណើត
- សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម (ផ្សារភ្ជាប់នឹងមន្ទីរពិសោធន៍)
- សមត្ថភាពផ្តល់សេវាសំរាលប្រកបដោយសុវត្ថិភាព និងថែទាំទារក
- ផ្សារភ្ជាប់ជាមួយនឹងសេវា OI/ART

ជាការមួយកាន់តែប្រសើរ ប្រសិនជាមានមណ្ឌលមិត្តជួយមិត្ត និងក្រុមថែទាំអ្នកជំងឺអេដស៍តាមផ្ទះ និងនៅតាមសហគមន៍។

បុគ្គលិកមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកនឹងចុះធ្វើការវាយតំលៃប៉ាន់ស្មាន សំរាប់មណ្ឌលដែលស្នើសុំដំណើរការកម្មវិធីបង្ការ ការចំលងមេរោគអេដស៍ពីម្តាយទៅកូន។ ការចុះវាយតំលៃប៉ាន់ស្មានធ្វើឡើងដើម្បី :

- អង្កេតមន្ទីរពេទ្យ ឬមណ្ឌលសុខភាពថាតើមានបន្ទប់សំរាប់ការផ្តល់ប្រឹក្សាជាលក្ខណៈឯកជនដែរឬទេ និង កំណត់ ថាតើបន្ទប់នោះត្រូវការជួសជុលដែរឬទេ។
- ធ្វើការវាយតំលៃពីធនធានមនុស្សដែលកំពុងបំរើការក្នុងពេលបច្ចុប្បន្ន
- ស្វែងយល់ពីអត្រាប្រើប្រាស់សេវាពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាព
- វិភាគពីចំណុចខ្លាំង និងឧបសគ្គនានា សំរាប់ដំណើរការកម្មវិធីនៅឯមូលដ្ឋាន

(បញ្ជីសំណួរសំរាប់ការចុះវាយតំលៃប៉ាន់ស្មានពីកន្លែងដែលនឹងដំណើរការកម្មវិធីមាននៅក្នុងឧបសម្ព័ន្ធG)។

មណ្ឌលសុខភាពទាំងអស់ដែលដំណើរការកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវមានបន្ទប់ដាច់ដោយឡែកសំរាប់ការផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ មុនពេលសម្ភោធឱ្យដំណើរការជាផ្លូវការ ដើម្បីធានាឱ្យបាននូវលក្ខណៈជាឯកជន និងលាក់ការសំងាត់ដល់អតិថិជន។ ការជួសជុលបន្ទប់នឹងរៀបចំឡើងដោយមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ប្រសិនបើចាំបាច់។

## ១០.២ ធនធានមនុស្ស

ជ្រើសរើសបុគ្គលិកសំរាប់ធ្វើការក្នុងកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនឱ្យបានសមស្រប គឺជាកិច្ចការគ្រប់គ្រងមួយដ៏សំខាន់។ អ្នកសំរបសំរួលកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនខេត្ត ត្រូវមានបទពិសោធន៍ការងារផ្នែកសុខភាពមាតានិងទារកនិងត្រូវបានជ្រើសរើសដោយប្រធានមន្ទីរសុខាភិបាលខេត្ត។ ប្រធានមន្ទីរសុខាភិបាល ស្រុកប្រតិបត្តិត្រូវចាត់តាំងឱ្យមានអ្នកសំរបសំរួលស្រុក និងប្រធានក្រុមនៅមណ្ឌលសុខភាព។ ក្រុមការងារផ្នែកបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនត្រូវជ្រើសរើសចេញពីបុគ្គលិកដែលមានចំណេះដឹងនិងបទពិសោធន៍ការងារផ្នែកសេវាសុខភាពមាតា និងទារក។ ក្រុមការងារបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនមាន :

- ប្រធានកម្មវិធី PMTCT ខេត្ត
- អ្នកសំរបសំរួល PMTCT ខេត្ត
- អ្នកសំរបសំរួល PMTCT ស្រុកប្រតិបត្តិ
- ប្រធានក្រុម PMTCT មណ្ឌលសុខភាព និង មន្ទីរពេទ្យបង្អែក
- អ្នកផ្តល់ប្រឹក្សានៅសេវាពិនិត្យផ្ទៃពោះ និង សម្ភព

ក្រុមការងារបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវធ្វើការជាមួយគ្នាលើការធ្វើផែនការ ការត្រៀមរៀបចំការអនុវត្តន៍ និង ការត្រួតពិនិត្យតាមដាន។ សមាសភាពទាំងអស់នេះគឺជាកត្តាចំបងសំរាប់អនុវត្តកម្មវិធីឱ្យបានជោគជ័យ។ (សូមមើលឧបសម្ព័ន្ធ រៀបរាប់ពីតួនាទីនិងភារកិច្ចរបស់អ្នកផ្តល់ប្រឹក្សា អ្នកសំរបសំរួលខេត្ត ប្រធានកម្មវិធីខេត្ត និងអ្នកសំរបសំរួលស្រុកប្រតិបត្តិ)។

## ១០.៣ ការបណ្តុះបណ្តាល

បុគ្គលិកនៃកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនទាំងអស់ ត្រូវទទួលការបណ្តុះបណ្តាលស្តីពីចំណេះដឹងជាមូលដ្ឋានស្តីពីមេរោគអេដស៍និងជំងឺអេដស៍និងការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន, ការផ្តល់ប្រឹក្សា, ការចិញ្ចឹមកូន និងអាហារូបត្ថម្ភបន្ថែម, ការបង្ការជាសកល និងការពន្យារកំណើត។ ការបណ្តុះបណ្តាលផ្សេងៗទៀតនឹងផ្តល់ជូននៅពេលត្រូវការចាំបាច់។ ការបណ្តុះបណ្តាលនឹងធ្វើការសហការរវាងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ អេដស៍ សើស្បែក និងកាមរោគ។ ការបណ្តុះបណ្តាលនេះ អនុវត្តតាមកម្មវិធីសិក្សាស្តង់ដា ដែលផលិតដោយមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក និង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។ បុគ្គលិកមន្ទីរពិសោធន៍នឹងទទួលការបណ្តុះបណ្តាលស្តីពីការធ្វើតេស្តឈាម ដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

## ១០.៤ សំភារៈបរិក្ខារនិងការផ្គត់ផ្គង់

ប្រព័ន្ធផ្គត់ផ្គង់សំភារៈនិងបរិក្ខារ ត្រូវបានរៀបចំឡើងដើម្បីធានាការផ្គត់ផ្គង់ឱ្យមានជាប់ជាប្រចាំសំរាប់កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន។ សំភារៈបរិក្ខារទាំងនោះ គួររាប់បញ្ចូលសំភារៈសំរាប់ការបង្ការជាសកលសំភារៈសំរាប់បូមឈាម និង ឱសថចាំបាច់ដទៃទៀត (រួមទាំងឱសថបង្ការប្រឆាំងមេរោគអេដស៍) និង ការផ្គត់ផ្គង់ដទៃទៀត (សូមមើលតារាងខាងក្រោម)។ រាល់ការផ្គត់ផ្គង់សំភារៈបរិក្ខារនឹងធ្វើឡើងតាមរយៈឃ្លាំងឱសថកណ្តាលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ឬពីដៃគូដែលជាម្ចាស់ជំនួយ។ អ្នកសំរបសំរួលកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនខេត្ត ជាអ្នកទទួលខុសត្រូវក្នុងការផ្គត់ផ្គង់សំភារៈ និងឧបករណ៍ដល់មណ្ឌលនិមួយៗ។

**សំភារៈដែលត្រូវការសំរាប់មណ្ឌលបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនមាន:**

| | |
|---|---|
| **សំភារៈសំរាប់ការិយាល័យ** | |
| ទូសំរាប់ដាក់ឯកសារ | ធុងសំរាម |
| កៅអីសំរាប់ផ្តល់ប្រឹក្សា | ប័ណ្ណបញ្ជូន |
| តុសំរាប់ផ្តល់ប្រឹក្សា | កិច្ចព្រមព្រៀង |
| សៀវភៅចុះឈ្មោះ | ឯកសារផ្សេងៗ |
| **សំភារៈសំរាប់ការពារបុគ្គលិក** | |
| ស្រោមដៃ | ស្បែកជើងការពារ |
| អៀមកៅស៊ូ | អាវពាក់ការពារពីក្រៅមិនជ្រាបទឹក |
| វ៉ែនតាការពារភ្នែក | |
| **សំភារៈដទៃទៀត** | |
| សំភារៈផ្សព្វផ្សាយពតិមាន (បើសិនជាមាន) | ឧបករណ៍ រំងាប់មេរោគ |
| អាល់កុល ៩៥% | ម្ជុល និងសឺរ៉ាំង |
| បំពង់ដាក់ឈាម | ធុងសំរាប់ដាក់របស់ស្រួច |
| សាប៊ូសំលាប់មេរោគ | ស៊ីរ៉ូប ណេវីរ៉ាពីន |
| បង់ Compress | ថ្នាំគ្រាប់ ណេវីរ៉ាពីន |
| លិង្គសិប្បនិម្មិត | ស៊ីរ៉ូប ZDV |
| ស្រោមអនាម័យ | ZDV គ្រាប់ |
| ថង់ផ្លាស្ទិកដាក់សំរាប់ដាក់សំភារៈសើម | 3TC គ្រាប់ |

**រៀបរៀងដោយក្រុមការងារបច្ចេកទេសនៃកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន, ខែសីហា ២០០២**

**កែសំរួលឡើងវិញដោយក្រុមការងារបច្ចេកទេសនៃកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន,ខែកញ្ញា២០០៥**

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ A : លិខិតព្រមព្រៀងសំរាប់ធ្វើតេស្តឈាម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ-សាសនា-ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក**

### កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន

### លិខិតអនុញ្ញាត

ខ្ញុំឈ្មោះ.......................................................................លេខកូដ...........................................................................

អាស័យដ្ឋាន.........................................................................................................................................................

...........................................................................................................................................................................

សូមបញ្ជាក់ថា:

១) - ខ្ញុំបានទទួលពតិមានគ្រប់គ្រាន់ស្តីពីកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ពីអ្នកផ្តល់ប្រឹក្សា

២) - ខ្ញុំបានយល់ព្រមធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត

៣) - លទ្ធផលតេស្តត្រូវរក្សាយ៉ាងសំងាត់ដោយអ្នកផ្តល់ប្រឹក្សា

៤) - ខ្ញុំមានសិទ្ធិប្តឹងចំពោះបុគ្គលណាដែលផ្សព្វផ្សាយពតិមានដោយគ្មានសុំការអនុញ្ញាតពីខ្ញុំ

៥) - ខ្ញុំមានសិទ្ធិបដិសេធនូវរាល់ចំណុចណាមួយនៅក្នុងលិខិតនេះ

ថ្ងៃ..........ខែ..............ឆ្នាំ................

ហត្ថលេខារបស់អតិថិជន.............................................. ឈ្មោះ..............................................................

ហត្ថលេខារបស់អ្នកផ្តល់ប្រឹក្សា....................................... ឈ្មោះ..............................................................

# ឧបសម្ព័ន្ធ B : របបឱសថបង្ការប្រឆាំងមេរោគអេដស៍ សំរាប់បង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន

| ឱសថ | ពេលមានផ្ទៃពោះ | ពេលកំពុងសំរាល | ក្រោយសំរាល | ក្រោយកើត |
|---|---|---|---|---|
| | ម្តាយ | ម្តាយ | ម្តាយ | កូន |
| HAART | HAART | HAART | HAART | NVP (2mg/kg) ផឹកភ្លាមក្រោយកើត ZDV(4mg/kg) ២ដង ក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ* |
| ZDV និង NVP | ZDV (300mg) លេប២ដងក្នុង១ថ្ងៃ។ ចាប់ប្រើនៅពេលគភ៌មាន អាយុ២៨អាទិត្យ ឬឱ្យលេបភ្លាមបើលើស ពី ២៨ អាទិត្យ | ZDV (300mg) លេបនៅពេលឈឺពោះសំរាលរាល់៣ម៉ោងម្តង រហូតដល់សំរាលនិង NVP (200mg)តែ១គ្រាប់គត់នៅពេលឈឺពោះសំរាល | ZDV (300mg) និង3TC (150mg) ២ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ | NVP (2mg/kg) ផឹកភ្លាមក្រោយកើត និង ZDV (4mg/kg) ផឹក២ដងក្នុង១ថ្ងៃ ឱ្យរយៈពេល៧ថ្ងៃ** |
| ZDV និង ឬ NVP សំរាប់កូន (នៅពេលម្តាយមិនបានទទួលឱសថបង្ការប្រឆាំងមេរោគអេដស៍) | គ្មាន | គ្មាន | គ្មាន | NVP (2mg/kg) ផឹកភ្លាមក្រោយកើត និង ZDV (4mg/kg) ផឹក ២ដង ក្នុង ១ថ្ងៃ រយៈពេល ៤អាទិត្យ ។ |

* បើសិនជាម្តាយបានទទួលឱសថព្យាបាលប្រឆាំងមេរោគអេដស៍ HAART តិចជាង ៤អាទិត្យ នៅពេលមានផ្ទៃពោះ កូនត្រូវទទួល ZDVរយៈពេល៤អាទិត្យ ។

**បើសិនជាម្តាយបានទទួល ZDVតិចជាង៤អាទិត្យនៅពេលមានផ្ទៃពោះ កូនត្រូវទទួលZDV រយៈពេល៤អាទិត្យ ។

*Adapted from: WHO/CDC, 2004. Prevention of Mother-to-Child Transmission of HIV Generic Training Package.*

# ឧបសម្ព័ន្ធ C : លិខិតបញ្ជូនសំរាប់ប្រើនៅ សេវាពិនិត្យផ្ទៃពោះ-អាគារពិនិត្យជំងឺក្រៅ

## កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន
## លិខិតបញ្ជូនពីសេវាពិនិត្យផ្ទៃពោះ-ពិនិត្យជំងឺក្រៅ

ឈ្មោះមណ្ឌលសុខភាព : ......................................................................................................

ស្រុក.................................................................. ខេត្ត.................................................................

លេខកូដអតិថិជន : ..............................................................................................................

| | |
|---|---|
| ឈ្មោះអ្នកបញ្ជូនៈ | ហត្ថលេខាៈ |
| ឈ្មោះអ្នកជំងឺ.......................................................................................................<br>អាស័យដ្ឋាន.......................................................................................................<br>....................................................................................................................... | |
| វដ្តរដូវចុងក្រោយ : [__]__] [__]__] [__]__]__]__]<br>ថ្ងៃប្រហាក់ប្រហែលសំរាល [__]__] [__]__] [__]__]__]__] | |
| ការព្យាបាល/បង្ការដោយឱសថប្រឆាំងមេរោគអេដស៍នៅពេលមានផ្ទៃពោះ<br><br>ថ្ងៃចាប់ផ្តើមប្រើ :.......................................... | |
| កំណត់ចំណាំ : | |

*បញ្ជូនទៅសេវា :* *អាស័យដ្ឋាន*

*OI/ART* ☐.......................................................................

*TB/HIV* ☐.......................................................................

*MMM* ☐.......................................................................

*HBC* ☐.......................................................................

*FBO* ☐.......................................................................

*OTHERS* ☐.......................................................................

# ឧបសម្ព័ន្ធ D : លិខិតបញ្ជូនពីសេវាពិនិត្យជំងឺក្រៅទៅ....

## កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន

## លិខិតបញ្ជូន

ឈ្មោះមណ្ឌលសុខភាព :......................................................................................................................

ស្រុក..................................................ខេត្ត...........................................................

លេខកូដអតិថិជន:............................................................................................................................

កាលបរិច្ឆេទ:...................................................................................................................................

ឈ្មោះអតិថិជន:..................................................អាយុ.................................................................

អាស័យដ្ឋាន:...................................................................................................................................

.........................................................................................................................................................

រោគសញ្ញាដែលសង្កេតឃើញ:.......................................................................................................

.........................................................................................................................................................

.........................................................................................................................................................

.........................................................................................................................................................

លទ្ធផលពីមន្ទីរពិសោធន៍:

ថ្ងៃខែឆ្នាំធ្វើតេស្ត:..............................................................................................................................

Hb…......…………………………Platelet………………………HVB/HVC……...................…

CD4………………………..........ផ្សេងៗ.....................................................................................

**អ្នកជំងឺព្យាបាលដោយ** ARV:

HAART: ☐ មាន **(រៀបរាប់ឈ្មោះថ្នាំ)..................................................** ☐ មិនមាន

ពេលផ្តើមប្រើថ្នាំ: ថ្ងៃ..................ខែ.......................ឆ្នាំ........................

កំណត់សំគាល់:.................................................................................................................................

.........................................................................................................................................................

.........................................................................................................................................................

.........................................................................................................................................................

ទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាល: ☐ មាន

(រៀបរាប់ឈ្មោះ)...........................................................☐ មិនមាន

ថ្ងៃខែណាត់ជួបលើកក្រោយ:.............................................................................................................

ឈ្មោះគ្រូពេទ្យពិនិត្យ:........................................................ហត្ថលេខា....................................................

# ឧបសម្ព័ន្ធ E : បញ្ជីផ្ទៀងផ្ទាត់តាមដានប្រចាំខែសំរាប់មូលដ្ឋាន

*របាយការណ៍នេះត្រូវបំពេញដោយអ្នកសំរបសំរួលកម្មវិធីថ្នាក់ស្រុកប្រតិបត្តិ*

១. កាលបរិច្ឆេទនៃការចុះអភិបាលៈ..........................................................................................

២. ទីកន្លែងៈ (ភ្នំពេញ ឬខេត្ត)................................................................................................

ក) - ស្រុក.................................................................................................................

ខ) - មន្ទីរពេទ្យ..........................................................................................................

គ) - មណ្ឌលសុខភាព...................................................................................................

៣. ឈ្មោះប្រធានក្រុម.................................................................................................................

៤. សូមពិនិត្យសំភារៈដូចតទៅនេះ :

| ល.រ | សំភារៈ | មាន | គ្មាន |
|---|---|---|---|
| ១ | សៀវភៅបញ្ជី | | |
| ២ | លិខិតអនុញ្ញាត | | |
| ៣ | ប័ណ្ណផ្តល់ប្រឹក្សា | | |
| ៤ | ក្រដាស់បិទលេខកូដ | | |
| ៥ | ប័ណ្ណណាត់ជួបទទួលលទ្ធផល | | |
| ៦ | ប័ណ្ណបញ្ជូនទៅមន្ទីរពិសោធន៍ | | |
| ៧ | លិខិតបញ្ជូន | | |
| ៨ | ស្រោមសំបុត្រ | | |
| ៩ | សំភារៈសំរាប់បូមឈាម | | |
| ១០ | ស្រោមដៃ | | |
| ១១ | លិង្គសិប្បនិម្មិត | | |
| ១២ | ស្រោមអនាម័យ | | |
| ១៣ | សំភារៈផ្សព្វផ្សាយពតិមាន | | |
| ១៤ | ប្រអប់សុវត្ថិភាព | | |

៥. ការសង្កេតនៅសេវាពិនិត្យផ្ទៃពោះ និងបន្ទប់អប់រំម្ដាយ: សូមពិនិត្យពីបែបបទនៃការអនុវត្តន៍ដូចតទៅនេះ:

| ល.រ | ការអប់រំម្ដាយ | មាន | គ្មាន |
|---|---|---|---|
| ១ | ស្វាគមន៍ និងបដិសណ្ឋារកិច្ច | | |
| ២ | អប់រំសុខភាពទូទៅ | | |
| ៣ | ពន្យល់ពីការពន្យារកំណើត | | |
| ៤ | ពន្យល់ពីអាហារូបត្ថម្ភ | | |
| ៥ | ពន្យល់ពីការចិញ្ចឹមកូន | | |
| ៦ | ពន្យល់ពីមេរោគអេដស៍-ជំងឺអេដស៍ និងកាមរោគ | | |
| ៧ | ពន្យល់ពីកម្មវិធីបង្ការការចំលងមេរោគរអេដស៍ពីម្ដាយទៅកូន និងការធ្វើតេស្តឈាម | | |

| ល.រ | វាយតំលៃពីការពិនិត្យសុខភាព | មាន | គ្មាន |
|---|---|---|---|
| ១ | វាស់កំពស់ និងថ្លឹងទំងន់ស្ត្រីមានផ្ទៃពោះ | | |
| ២ | វាស់សម្ពាធឈាមស្ត្រី | | |
| ៣ | ពិនិត្យមើលទំរង់កូន | | |
| ៤ | ពិនិត្យរកចង្វាក់បេះដូងកូន | | |
| ៥ | រាវរកសញ្ញាគ្រោះថ្នាក់ដែលអាចកើតឡើងពេលមានផ្ទៃពោះ | | |
| ៦ | សួរពីបញ្ហាទាក់ទងនឹងផ្ទៃពោះ | | |
| ៧ | រាវរកសញ្ញាជំងឺកាមរោគ | | |
| ៨ | ចាក់ថ្នាំតេតាណុសដល់ស្ត្រីមានផ្ទៃពោះ | | |

៦. សូមពិនិត្យមើលសំភារៈនៅផ្នែកសំរាលដូចតទៅនេះ:

| ល.រ | សំភារៈ | មាន | គ្មាន |
|---|---|---|---|
| ១ | សៀវភៅបញ្ជី | | |
| ២ | ឯកសារនៅក្នុងទូចាក់សោរ | | |
| ៣ | ឱសថបង្ការប្រឆាំងមេរោគអេដស៍សំរាប់ម្ដាយ | | |
| ៤ | ឱសថបង្ការប្រឆាំងមេរោគអេដស៍សំរាប់កូន | | |
| ៥ | ស្រោមដៃ | | |
| ៦ | ស្បែកជើងការពារមិនជ្រាបទឹក | | |
| ៧ | អៀមកៅស៊ូពាក់សំរាប់ការពារ | | |

| | | | |
|---|---|---|---|
| ៨ | បណ្ណលឿងចាក់វ៉ាក់សាំងកុមារ | | |
| ៩ | វ៉ែនតាពាក់ការពារភ្នែក | | |
| ១០ | សារធាតុគីមីសំលាប់មេរោគ | | |
| ១១ | សំភារៈដែលរំងាប់មេរោគមុននឹងយកមកប្រើ | | |
| ១២ | បន្ទប់សំរាលរំងាប់មេរោគ | | |
| ១៣ | ប្រអប់សុវត្ថិភាព | | |

៧. តើពតិមាននិងទិន្នន័យនៅក្នុងបញ្ជីនៃ សេវាពិនិត្យផ្ទៃពោះ និងសេវាសំរាលបានកត់ត្រាត្រឹមត្រូវនិងរាល់ថ្ងៃដែរឬទេ?

..............................................................................................................................................

៨.កាលបរិច្ឆេទផុតកំណត់នៃឱសថ NVP ស៊ីរ៉ូប?....................................................................................

៩.កាលបរិច្ឆេទផុតកំណត់នៃឱសថ NVP គ្រាប់?....................................................................................

១០.កាលបរិច្ឆេទផុតកំណត់នៃឱសថ ZDV ស៊ីរ៉ូប?..................................................................................

១១.កាលបរិច្ឆេទផុតកំណត់នៃឱសថ ZDV គ្រាប់?..................................................................................

| បញ្ហាផ្សេងៗ: |
|---|
| |

# ឧបសម្ព័ន្ធ F : បញ្ជីផ្ទៀងផ្ទាត់សំរាប់ការចុះអភិបាល

ផ្នែកទី ១ :

១-ថ្ងៃខែឆ្នាំចុះអភិបាលៈ ពីថ្ងៃទី............ខែ..............ឆ្នាំ...................ដល់ថ្ងៃទី..........ខែ.........ឆ្នាំ...............

២-ទីកន្លែង (ភ្នំពេញ/ខេត្ត) ..............................................................................................................

ស្រុក..................................មណ្ឌលសុខភាព..................................មន្ទីរពេទ្យ....................................

៣-ឈ្មោះអ្នកចុះអភិបាលៈ

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

៤-ពេលវេលាធ្វើការ :

ពេលព្រឹកចាប់ពីម៉ោង...........................................ដល់ម៉ោង......................................................

ពេលល្ងាចចាប់ពីម៉ោង..........................................ដល់ម៉ោង......................................................

៥-ការរៀបចំបន្ទប់ផ្តល់ប្រឹក្សា និងសំភារៈសំរាប់អប់រំ :

| ល.រ | ការរៀបចំបន្ទប់ | មាន | គ្មាន | យោបល់របស់អ្នកអភិបាល |
|---|---|---|---|---|
| ១ | បន្ទប់ផ្តល់ប្រឹក្សាឯកជន | | | |
| ២ | ទូដាក់លទ្ធផលតេស្ត | | | |

| ល.រ | សំភារៈ | មាន | គ្មាន |
|---|---|---|---|
| ១ | បញ្ជីកត់ត្រា | | |
| ២ | លិខិតយល់ព្រមធ្វើតេស្តឈាម | | |
| ៣ | ឯកសារផ្តល់ប្រឹក្សា | | |
| ៤ | ប័ណ្ណសំគាល់ខ្លួនអតិថិជន | | |
| ៥ | ក្រដាស់បិទលេខកូដ | | |
| ៦ | ប័ណ្ណបញ្ជូនទៅមន្ទីរពិសោធន៍ | | |
| ៧ | លិខិតបញ្ជូន | | |
| ៨ | ឧបករណ៍សំរាប់ធ្វើតេស្តឈាម | | |
| ៩ | ស្រោមដៃ | | |

| | | | |
|---|---|---|---|
| ១០ | លិង្គសិប្បនិម្មិត | | |
| ១១ | ស្រោមអនាម័យ | | |
| ១២ | សំភារៈសំរាប់ផ្សព្វផ្សាយពត៌មាន | | |
| ១៣ | ប្រអប់សុវត្ថិភាព | | |
| ១៤ | ឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលង | | |
| ១៥ | ស្រោមសំបុត្រ | | |

៦-ការសង្កេតពីការផ្តល់ប្រឹក្សា: រាល់ចំលើយដែលមាននៅក្នុងចំណុចនិមួយៗ សូមដាក់ពិន្ទុ ពីលេខ១-៥។ លេខ១មានន័យថាអន់បំផុត។ លេខ៥មានន័យថា ល្អឥតខ្ចោះ។

| ល.រ | ការអប់រំម្តាយ | មាន | ពិន្ទុ | គ្មាន |
|---|---|---|---|---|
| ១ | ស្វាគមន៍ និងបដិសណ្ឋារកិច្ច | | | |
| ២ | អប់រំសុខភាពទូទៅ | | | |
| ៣ | ពន្យារកំណើត | | | |
| ៤ | ពន្យល់ពីអាហារូបត្ថម្ភ | | | |
| ៥ | អប់រំពីការបំបៅដោះកូន | | | |
| ៦ | ពន្យល់ពីជំងឺកាមរោគ មេរោគអេដស៍-ជំងឺអេដស៍ | | | |
| ៧ | ពន្យល់ពីកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន និង ការប្រឹក្សាធ្វើតេស្តឈាម | | | |

| ល.រ | ការពិនិត្យសុខភាព | មាន | ពិន្ទុ | គ្មាន |
|---|---|---|---|---|
| ១ | វាស់កំពស់ និង ទំងន់ | | | |
| ២ | វាស់សម្ពាធឈាម | | | |
| ៣ | សួរនាំពីជំងឺផ្សេងៗទាក់ទងទៅនឹងផ្ទៃពោះ | | | |
| ៤ | ពិនិត្យរកសញ្ញាគ្រោះថ្នាក់ផ្សេងៗ | | | |
| ៥ | រាវរកសញ្ញានៃជំងឺកាមរោគ | | | |
| ៦ | ចាក់ថ្នាំបង្ការតេតាណុសដល់ស្ត្រីមានគភ៌ | | | |
| ៧ | ពិនិត្យមើលចង្វាក់បេះដូងកូន | | | |
| ៨ | ពិនិត្យមើលទំរង់កូន | | | |

៧-តើឆ្មបចាត់វិធានការបែបណា នៅពេលឃើញមានរោគសញ្ញានៃជំងឺផ្សេងៗ ដែលទាក់ទងទៅនឹងផ្ទៃពោះ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

៨-សូមពិនិត្យមើលតើមន្ទីរពេទ្យបង្អែកមានអ្វីខ្លះ?

Hb ☐ Ht ☐ Syphilis ☐ គោលិកាស ☐ ទឹកនោម(Alb, Glucose) ☐ មុខងារថ្លើម ☐ អេកូសាស្ត្រ ☐

៩-តើលទ្ធផលតេស្តមានបិទស្រោមសំបុត្រឬទេ? មាន ☐ មិនមាន ☐

១០-តើមានសញ្ញាណាមួយនៅលើស្រោមសំបុត្រដែលបញ្ជាក់ពីស្ថានភាពផ្ទុកមេរោគអេដស៍របស់អតិថិជនដែរឬទេ?

មាន ☐ (សូមពន្យល់).........................................................................មិនមាន ☐

១១-តើរយៈពេលនៃការទទួលលទ្ធផលយូរប៉ុណ្ណា? បើសិនជាមិនបានផ្តល់ឱ្យក្នុងថ្ងៃតែមួយ តើមកពីមូលហេតុអ្វី?

.....................................................................................................................................

.....................................................................................................................................

១២-តើពីមន្ទីរពិសោធន៍ទៅកន្លែងពិនិត្យផ្ទៃពោះមានចំងាយប៉ុន្មាន?..................................................................

**ការបញ្ជូន**

១៣-បើសិនជាធ្វើរោគវិនិច្ឆ័យឃើញថា អតិថិជនមានជំងឺកាមរោគឬជំងឺអេដស៍ តើមានស្នើឱ្យគាត់នាំប្តីមកពិនិត្យនិងព្យាបាលដែរឬទេ? មាន ☐ មិនមាន ☐

១៤-តើស្ត្រីដែលមានផ្ទុកមេរោគអេដស៍ មានបញ្ជូនទៅក្រុមថែទាំតាមផ្ទះដែរឬទេ? មាន ☐ មិនមាន ☐

១៥-តើស្ត្រីដែលមានផ្ទុកមេរោគអេដស៍ មានបញ្ជូនទៅក្រុមមិត្តជួយមិត្តដែរឬទេ? មាន ☐ មិនមាន ☐

១៦-តើស្ត្រីមានផ្ទុកមេរោគអេដស៍ មានបញ្ជូនទៅសេវា OI/ART ដែរឬទេ? មាន ☐ មិនមាន ☐

១៧-តើស្ត្រីមានផ្ទុកមេរោគអេដស៍ មានបញ្ជូនទៅសេវាជំងឺរបេងដែរឬទេ? មាន ☐ មិនមាន ☐

**នៅសេវាសម្ភព**

| ល.រ | សំភារៈ | មាន | គ្មាន |
|---|---|---|---|
| ១ | សៀវភៅបញ្ជីកត់ត្រា | | |
| ២ | ទូដាក់ឯកសារ | | |
| ៣ | ឱសថប្រឆាំងមេរោគអេដស៍បង្ការ ការចំលងសំរាប់ម្តាយ | | |

| | | | |
|---|---|---|---|
| ៤ | ឱសថប្រឆាំងមេរោគអេដស៍បង្ការការចំលងសំរាប់ទារក | | |
| ៥ | ស្រោមដៃ | | |
| ៦ | ស្បែកជើងពាក់ការពារ | | |
